អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

**Action for Research and Development ‘ARD’**

# វគ្គគ្រប់គ្រងគំរោង

# Project Management Training Course

**ខែឧសភា ឆ្នាំ ២០០៦**

អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

**Action for Research and Development ‘ARD’**

# វគ្គគ្រប់គ្រងគំរោង

# Project Management Training Course

**រៀបចំឡើងដោយ**

**កម្មវិធីពង្រឹងសមត្ថភាព ស្រាវជ្រាវ និងបោះពុម្ព**

**Prepared by**

**Capacity Building, Research and Publication Program**

# មាតិកា


**សេចក្តីផ្តើមនៃការគ្រប់គ្រងគំរោង........................................................... ១**

តើគំរោងគឺជាអ្វី?............................................................................................ ១

ប្រភេទគំរោង.................................................................................................. ២

ការគ្រប់គ្រងគំរោង........................................................................................... ៣

អ្នកគ្រប់គ្រងគំរោង.......................................................................................... ៤

វដ្តគំរោង....................................................................................................... ៥

**ការធ្វើផែនការគំរោង............................................................................ ៩**

គុណសម្បត្តិ នៃការប្រើប្រាស់ OOPP ................................................................ ១០

គុណវិបត្តិនៃការប្រើប្រាស់ OOPP ..................................................................... ១១

ការធ្វើផែនការជាមួយ OOPP ........................................................................... ១១

**ការវិភាគស្ថានភាព................................................................................. ១៣**

ការវិភាគពីការចូលរួម....................................................................................... ១៣

ការវិភាគបញ្ហា................................................................................................ ១៤

ការវិភាគគោលបំណង....................................................................................... ១៥

ការវិភាគរកវិធីដោះស្រាយនានា......................................................................... ១៦

**ការរៀបចំបង្កើតគំរោង.......................................................................... ១៧**

Logical Framework........................................................................................ ១៧

ធាតុនៅក្នុង Logical Framework ..................................................................... ១៨

គោលបំណងរួម Overal Objective..................................................................... ១៨

គោលបំណងគំរោង Immediate Objective .......................................................... ១៩

លទ្ធផល Output............................................................................................. ២០

សកម្មភាព និងពេលវេលា Activity .................................................................... ២០

សន្ទស្សន៍ Indicator......................................................................................... ២១

មធ្យោបាយផ្ទៀងផ្ទាត់ Means of Verification....................................................... ២១

កត្តាខាងក្រៅ External Factor/Assumption........................................................ ២១

**ផែនការសកម្មភាព........................................................................ ២៥**

តើសកម្មភាពជាអ្វី?.......................................................................................... ២៥

លក្ខណៈរបស់សកម្មភាព.................................................................................. ២៥

ជំហានក្នុងការបង្កើតសកម្មភាព.......................................................................... ២៥

ផែនការសកម្មភាព........................................................................................... ២៥

**ការរៀបចំផែនការថវិកា.................................................................. ២៨**

តើផែនការថវិកាជាអ្វី?...................................................................................... ២៨

អត្ថប្រយោជន៍ នៃការរៀបចំថវិកាគំរោង............................................................... ២៨

ចំនុចសំខាន់ៗ ដែលត្រូវយកចិត្តទុកដាក់ក្នុងពេលរៀបចំថវិកា.................................. ២៨

ប្រភេទ នៃដំណើរការរៀបចំថវិកា........................................................................ ៣០

**ការត្រួតពិនិត្យ និងវាយតំលៃគំរោង................................................... ៣១**

ការត្រួតពិនិត្យជាអ្វី?....................................................................................... ៣១

ការត្រួតពិនិត្យកម្មវិធី....................................................................................... ៣១

ការត្រួតពិនិត្យការគ្រប់គ្រងអង្គការ...................................................................... ៣១

ហេតុអ្វីចាំបាច់ធ្វើការត្រួតពិនិត្យ......................................................................... ៣២

ជំហាន នៃការត្រួតពិនិត្យ................................................................................... ៣៣

ការវាយតំលៃ................................................................................................. ៣៤

តើអ្នកណាអាចធ្វើការវាយតំលៃ........................................................................... ៣៥

តើការវាយតំលៃសំរាប់អ្នកណា?.......................................................................... ៣៦

តើពេលណាគួរធ្វើការវាយតំលៃ.......................................................................... ៣៧

ជំហាន នៃការវាយតំលៃ.................................................................................... ៣៩

**ការបញ្ចប់គំរោង............................................................................ ៤៤**

សេចក្តីផ្តើម.................................................................................................... ៤៤

គំរោងជោគជ័យ រឺបរាជ័យ.................................................................................. ៤៤

មូលហេតុនៃការបញ្ចប់គំរោង.............................................................................. ៤៤

ប្រភេទនៃការបញ្ចប់គំរោង.................................................................................. ៤៥

យុទ្ធសាស្ត្រនៃការបញ្ចប់.................................................................................... ៤៦

**ការណែនាំដំបូងអំពីការបង្កើតសំណើគំរោង................................................ ៤៨**

គំរូទំរង់បែបបទសំរាប់ការសរសេរសំណើរគំរោង........................................ ៤៩

ទំព័រចំណងជើង........................................................................................ ៥០

ខ្លឹមសារសង្ខេប........................................................................................ ៥០

បញ្ជីមាតិកា............................................................................................. ៥១

សន្ទានុក្រម.............................................................................................. ៥១

សេចក្តីផ្តើម.............................................................................................. ៥១

សេចក្តីថ្លែងពីបញ្ហា..................................................................................... ៥១

វិធីសាស្រ្ត (សកម្មភាព)................................................................................. ៥២

គំរោងថវិកាសង្ខេប...................................................................................... ៥២

ផែនការត្រួតពិនិត្យ វាយតំលៃ របាយការណ៍.............................................. ៥៣

ឯកសារភ្ជាប់ (ឧបសម្ព័ន្ធ).............................................................................. ៥៤

**ឯកសារយោង.................................................................................... ៥៥**

**កាលវិភាគ**

**វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងគំរោង**

| **ម៉ោង** | **ប្រធានបទ** | **វិធីសាស្រ្ត** | **សំភារះ** |
|---|---|---|---|
| **ថ្ងៃទី១ (រយះពេល ៤ ម៉ោង)** | | | |
| ០៨:០០-០៨:៣០ | សំនួរសរសេរសាកល្បងមុនពេលចាប់ផ្តើមវគ្គ | | |
| ០៨:៣០-០៩:០០ | ការបង្ហាញលទ្ធផលរពឹងទុករបស់សិក្ខាកាម និងកាលវិភាគសំរាប់វគ្គការគ្រប់គ្រងគំរោង | បង្ហាញតាមក្រដាសផ្ទាំងធំ | ក្រដាសផ្ទាំងធំ |
| ០៩:០០-១០:០០ | សេចក្តីផ្តើមអំពីការគ្រប់គ្រងគំរោង<br>- តើអ្វីជាគំរោង?<br>- តើអ្វីជាការគ្រប់គ្រងគំរោង? | បំផុសគំនិត | ក្រដាសផ្ទាំងធំ, ក្រដាសកាត |
| ១០:០០-១០:១៥ | សំរាក | | |
| ១០:១៥-១២:០០ | សេចក្តីផ្តើមអំពីការគ្រប់គ្រងគំរោង<br>- ហេតុអ្វីបានជាត្រូវរៀនអំពីការគ្រប់គ្រងគំរោង<br>- អ្នកគ្រប់គ្រងគំរោងគំរោង<br>- វដ្ត នៃគំរោង | ពិភាក្សាតាមក្រុម២-៤នាក់ | ក្រដាសបង្ហូចចូហារី |
| **ថ្ងៃទី ២ (រយះពេល ៤ ម៉ោង)** | | | |
| ០៨:០០-០៨:៣០ | រំលឹកមេរៀន | | |
| ០៨:៣០-០៩:០០ | ជំហាន នៃការធ្វើផែនការគំរោង | បំផុសគំនិត | |
| ០៩:០០-១០:១៥ | ការធ្វើផែនការគំរោងដោយផ្អែកលើគោលបំណង<br>- ការវិភាគពីស្ថានភាព<br>- ការវិភាគបញ្ហា | បំផុសគំនិត, ធ្វើបង្ហាញ | ក្រដាសផ្ទាំងធំ, ក្រដាសកាត |
| ១០:១៥-១០:៣០ | សំរាក | | |
| ១០:៣០-១២:០០ | ការធ្វើផែនការគំរោងដោយផ្អែកលើគោលបំណង<br>- ការវិភាគគោលបំណង<br>- ការវិភាគពីវិធីសាស្រ្តដំណោះស្រាយនានា | បំផុសគំនិត, ធ្វើបង្ហាញ | ក្រដាសផ្ទាំងធំ, ក្រដាសកាត |
| **ថ្ងៃទី៣ (រយះពេល ៤ម៉ោង)** | | | |

| | | | |
|---|---|---|---|
| ០៨:០០-១០:០០ | លំហាត់អនុវត្តជាក់ស្តែងពីការវិភាគពីស្ថានភាព | ពិភាក្សាជាក្រុម | |
| ១០:០០-១០:១៥ | សំរាក | | |
| ១០:១៥-១១:១៥ | ផែនការសកម្មភាព | បំផុសគំនិត | |
| ១១:១៥-១២:០០ | លំហាត់អនុវត្តជាក់ស្តែងពីការធ្វើផែនការសកម្មភាព | ពិភាក្សាជាក្រុម | |
| **ថ្ងៃទី ៤ (រយៈពេល ៤ ម៉ោង)** | | | |
| ០៨:០០-០៩:០០ | ផែនការថវិកា | បំផុសគំនិត | ក្រដាសកាត |
| ០៩:០០-១០:១៥ | លំហាត់អនុវត្តជាក់ស្តែងពីការធ្វើផែនការថវិកា | ពិភាក្សាជាក្រុម | |
| ១០:១៥-១០:៣០ | សំរាក | | |
| ១០:៣០-១២:០០ | ការតាមដាន និងវាយតំលៃគំរោង | បំផុសគំនិត | |
| **ថ្ងៃទី ៥ (រយៈពេល ៤ម៉ោង)** | | | |
| ០៨:០០-១០:៣០ | ការតាមដាន និងវាយតំលៃគំរោង (តចប់) | បំផុសគំនិត | |
| ១០:៣០-១០:៤៥ | សំរាក | | |
| ១០:៤៥-១២:០០ | ការណែនាំអំពីការសរសេរគំរោងស្នើសុំ | បំផុសគំនិត | |
| **ថ្ងៃទី ៦ (រយៈពេល ៤ម៉ោង)** | | | |
| ០៨:០០-០៩:៣០ | ការណែនាំអំពីការសរសេរគំរោងស្នើសុំ (តចប់) | | |
| ០៩:៣០-០៩:៤៥ | សំរាក | | |
| ០៩:៤៥-១២:០០ | លំហាត់អនុវត្តជាក់ស្តែងក្នុងការសេរសេរគំរោងស្នើសុំ | | |
| **ថ្ងៃទី ៧ (រយៈពេល ៤ម៉ោង)** | | | |
| ០៨:០០-០៩:០០ | រំលឹកមេរៀន | | |
| ០៩:០០-០៩:៣០ | សំរាក | | |
| ០៩:៣០-១១:៣០ | ការជ្រើសរើសប្រធានបទគំរោងដើម្បីសរសេរ និងការពារបញ្ចប់វគ្គ | | |
| ១១:៣០-១២:០០ | សំនួរសរសេរក្រោយពេលបញ្ចប់វគ្គ | | |

# សេចក្តីផ្តើម នៃការគ្រប់គ្រងគំរោង
# Introduction to Project Management

## ១. តើគំរោង គឺជាអ្វី? (What is a project?)

យើងទាំងអស់គ្នា សុទ្ធតែធ្លាប់បានឃើញ រឺក៏យ៉ាងហោចណាស់បានលឺអំពីការសាងសង់សាលារៀន, មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ទំនប់វារីអគ្គីសនី និងសកម្មភាពមួយចំនួនដូចជា កម្មវិធីបណ្តុះបណ្តាល, ការផ្សព្វផ្សាយកសិកម្ម ។ល។ ទាំងនេះ គឺជាលទ្ធផល នៃគំរោងប្រភេទផ្សេងៗគ្នា ។ គោលបំណងរួម នៃគំរោងទាំងនេះ គឺដើម្បីកែលំអជីវភាព/លក្ខណ្ឌរស់នៅរបស់ប្រជាជន ។

ជាធម្មតា គំរោងមានច្រើនវគ្គ ហើយនៅពេលខ្លះវាទាមទាររយៈពេលវែង មុននឹងអាចឈានទៅដល់វគ្គចុងក្រោយនៃគំរោង។ គោលបំណង នៃការសិក្សាលើប្រធានបទនេះ គឺចង់បង្ហាញថា តើយើងត្រូវធ្វើអ្វីខ្លះនៅក្នុងវគ្គនីមួយៗ នៃគំរោងដើម្បីអាចបង្កើនជំនាញក្នុងការធ្វើផែនការ និងការដំណើរការ នៃគំរោងផ្សេងៗ ដែលយើងត្រូវបំពេញ រឺចូលរួមចំណែកនៅក្នុងអាជីពរបស់យើងម្នាក់ៗ ។

មានអ្នកនិពន្ធជាច្រើន បានអោយអត្ថន័យផ្សេងៗគ្នាទៅលើពាក្យថា គំរោង :

- គំរោង មានន័យថាគឺជាគ្រោងការណ៍ រឺផ្នែកមួយ នៃគ្រោងការណ៍សំរាប់វិនិយោគធនធាន ដែលក្នុងនោះ វាអាចត្រូវបានគេវិភាគ និងវាយតំលៃយ៉ាងសមហេតុផលថាជាផ្នែកមួយដែលឯករាជ្យ (Little and Mirlees, 1980:3) ។

- គំរោង មានន័យថាជាធនធានពេញលេញមួយ ដែលគេដំណើរការដោយមានការសំរបសំរួលដើម្បីឈានទៅសំរេចគោលបំណងសេដ្ឋកិច្ចមួយដែលគេកំណត់ទុកជាមុន (Chervel and Le Gall, 1978:6) ។

- គំរោង គឺជាសំនុំ នៃសកម្មភាពដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ដែលនាំទៅដល់ការគ្រប់គ្រងជារួមមួយ ដើម្បីសំរេចនូវគោលបំណងជាក់លាក់ជាមួយនឹងថវិកា និងរយៈពេលកំណត់មួយ (និយមន័យរបស់ UNDP ដែលផ្តល់នៅ Sohm ឆ្នាំ ១៩៧៨) ។

- គំរោង គឺជាការធ្វើដោយមានផែនការ ជាការគ្រប់គ្រងមួយ ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នូវអ្វីដែលត្រូវបំពេញដោយប្រើពេលវេលា រយៈពេល និងតំលៃកំណត់មួយដែលគេប៉ាន់ប្រមាណទុក (និយមន័យរបស់ ILO ដែលផ្តល់នៅ Sohm ឆ្នាំ ១៩៧៨) ។

ចេញពីនិយមន័យទាំងប៉ុន្មានខាងលើនេះ យើងអាចកំណត់នូវពាក្យគន្លឹះមួយចំនួន ដែលពាក់ព័ន្ធនឹងដំណើរការ នៃការធ្វើផែនការគំរោងដូចតទៅ : **ការធ្វើផែនការ, ការវិនិយោគធនធាន, គោលបំណង, ផ្នែកឯករាជ្យ, ផលិតនូវប្រយោជន៍, ថវិកាកំណត់មួយ, រយៈពេល និងការកំណត់មួយ** ។ ដោយផ្អែកលើការសង្កេតទាំងនេះ យើងអាចអោយនិយមន័យរួមមួយដូចខាងក្រោម :

**គំរោង គឺជាសំណុំ នៃសកម្មភាពដែលទាក់ទងគ្នាទៅវិញទៅមក ហើយដែលប្រើប្រាស់ដោយមានកំណត់នូវធនធានថវិកា, មនុស្ស និងវត្ថុ ក្នុងកំឡុងពេលជាក់លាក់មួយ ដើម្បីផលិតនូវទំនិញ រឺសេវាក្នុងការសំរេចនូវគោលបំណងជាក់លាក់មួយ រឺច្រើន (Chervel and Le Gall, 1978:6) ។**

## ២. ប្រភេទគំរោង ( Types of Projects )

មានប្រភេទផ្សេងៗជាច្រើន នៃគំរោងដែលយើងបានជួបប្រទះនៅក្នុងការប្រកបវិជ្ជាជីវៈរបស់យើង ដែលខាងក្រោមនេះ គឺជាការលើកឡើងនូវការពិភាក្សាពីប្រភេទផ្សេងៗគ្នា នៃគំរោង :

### ២.១ ការចែកប្រភេទគំរោងដោយផ្អែកទៅលើលទ្ធផលសំរេចបានរបស់គំរោង (Based on the output)

គ្រប់គំរោងទាំងអស់សុទ្ធតែប្រើប្រាស់នូវធនធាន (Resources) ដើម្បីផលិតចេញជាភោគទ្រព្យ នៃសង្គម រឺហិរញ្ញវត្ថុ រឺសារៈសំខាន់ខាងសេដ្ឋកិច្ច（Output）។ ទំនាក់ទំនងរវាង Inputs ដែលមាន រឺប្រើនៅក្នុងគំរោងមួយ និងលទ្ធផល Output ដែលគំរោងនោះបានបង្កើតឡើង ត្រូវបានបង្ហាញ នៅក្នុងគំនូសតាងដូចខាងក្រោម :

**ធនធានដែលត្រូវប្រើ Inputs** ⟶ **គំរោង Project** ⟶ **លទ្ធផល Outputs**

（ធនធានហិរញ្ញវត្ថុ មនុស្ស និងសំភារៈ） （សកម្មភាព） （ភោគទ្រព្យ រឺសេវា）

ដោយយោងទៅតាមលទ្ធផល គេចែកគំរោង ជាពីរប្រភេទធំៗ គឺ :

#### ២.១.១ គំរោងដែលផលិតបាននូវលទ្ធផលជាភោគទ្រព្យ (Goods as Output)

គំរោងទាំងនេះ ប្រើប្រាស់នូវធនធាន និងផលិតនូវភោគទ្រព្យដែលជាវត្ថុ រឺរបស់របរដែលយើងអាចមើលឃើញ រឺប៉ះពាល់បាន។ ឧទាហរណ៍ គំរោងជីកអណ្តូងទឹកស្អាត, គំរោងសាងសង់ផ្លូវលំ ។ល។

#### ២.១.២ គំរោងដែលផលិតបាននូវលទ្ធផលជាសេវា (Services as Output)

ជំនួសអោយការផលិតភោគទ្រព្យ គំរោងទាំងនេះផ្តល់ជាសេវាទៅអោយមនុស្ស ។ ជាទូទៅ លទ្ធផលរបស់គំរោងទាំងនេះមិនអាចមើលឃើញ រឺប៉ះពាល់បានឡើយ។ ឧទាហរណ៍ សុខភាព និងការអប់រំ ជាផ្នែកនៃគំរោង

ប្រភេទនេះ ។ គំរោងបណ្តុះបណ្តាលជំនាញបច្ចេកទេសកសិកម្មដល់ប្រជាកសិករ, គំរោងស្រាវជ្រាវពីផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំពុលគីមី ។ល ។

### ២.២ ការចែកប្រភេទគំរោងដោយផ្អែកលើបំណង (Based on the Intention)

ដោយផ្អែកទៅលើបំណង នៃគំរោង គេចែកគំរោងជាពីរប្រភេទ :

#### ២.២.១ គំរោងរកប្រាក់ចំណេញ (Income Generating Project)

ក្នុងគំរោងនេះ គេប្រើប្រាស់នូវធនធានដើម្បីផលិតភោគទ្រព្យ រឺសេវា ដោយភ្ជាប់ជាមួយនឹងគោលបំណង ក្នុងការលក់នូវលទ្ធផលទាំងនេះ ដើម្បីទទួលបាននូវចំណូល ។ ការបង្កើតបានប្រាក់ចំណេញ គឺជាបំណងដ៏ធំរបស់គំរោងទាំងនេះ ។ គំរោងទាំងនេះ អាចត្រូវបានអនុវត្តដោយបុគ្គលឯកជន រឺអង្គការ រឺដោយរដ្ឋាភិបាល ។

#### ២.២.២ គំរោងមិនរកប្រាក់ចំណេញ (Non-Income Generating or Social Development Project)

គោលបំណងសំខាន់របស់គំរោងទាំងនេះ គឺដើម្បីធ្វើអោយប្រសើរឡើងនូវលក្ខណ្ឌសង្គមរបស់ប្រជាជន ។ គំរោងប្រភេទនេះ ក៏ប្រើប្រាស់ផងដែរនូវធនធាន ដើម្បីបង្កើតសេវាកម្មសំរាប់ជាប្រយោជន៍របស់ប្រជាជន ពេលខ្លះដោយឥតគិតថ្លៃ និងមានពេលខ្លះដោយគិតត្រឹមតំលៃមានតែឈ្មោះ ។ ការបង្កើតប្រាក់ចំណូល មិនមែនជាគោលបំណងទេ ប៉ុន្តែការចែកចាយសេវាកម្ម គឺជាគោលបំណងសំខាន់របស់គំរោងប្រភេទនេះ ។ ឧទាហរណ៍ គំរោងផ្គត់ផ្គង់ទឹកស្អាត គំរោងផ្សព្វផ្សាយកសិកម្ម ។ល ។

## ៣. ការគ្រប់គ្រងគំរោង

កត្តាសំខាន់ដែលនាំអោយគំរោងជោគជ័យ រឺបរាជ័យ គឺផ្អែកជាចាំបាច់ ទៅលើការគ្រប់គ្រងគំរោងដែលល្អ មានប្រសិទ្ធិភាព និងការគ្រប់គ្រងដែលមិនល្អ គ្មានប្រសិទ្ធិភាព ។

☛ **អត្ថន័យ នៃការគ្រប់គ្រងគំរោង :**

- **ការគ្រប់គ្រងគំរោង** គឺជាការធ្វើផែនការ ការរៀបចំចាត់ចែង ការដឹកនាំ និងត្រួតពិនិត្យធនធាន ដែលបានកំណត់អោយ សំរាប់គោលបំណងរយៈពេលកំណត់មួយ ដែលគេបានបង្កើតឡើងដើម្បីបំពេញប្រយោជន៍ និងគោលបំណងជាក់លាក់ ។ (AIT, CEE 1996)
- **ការគ្រប់គ្រងគំរោង** គឺជាដំណើរការ នៃការធ្វើផែនការ ការរៀបចំចាត់ចែង ការជ្រើសរើស និងគ្រប់គ្រងបុគ្គលិក ការតាមដាន ត្រួតពិនិត្យ និងការដឹកនាំគំរោង ។

តាមរយៈមុខងារសំខាន់ៗ ការគ្រប់គ្រងត្រូវបានធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម :

- ការធ្វើផែនការ Planning

- ការរៀបចំចាត់ចែងការងារ Organizing
- ការជំរុញលើកទឹកចិត្ត Motivation
- ការដឹកនាំ តំរង់ទិស Directing
- ការត្រួតពិនិត្យ Controlling

## ៤. អ្នកគ្រប់គ្រងគំរោង

គឺជាអ្នកដែលមានទួនាទីទទួលខុសត្រូវខ្ពស់បំផុត ចំពោះជោគជ័យ និងបរាជ័យរបស់គំរោង។ តួនាទីរបស់អ្នកគ្រប់គ្រង គឺធ្វើយ៉ាងណាដើម្បីសំរេចនូវគោលបំណងទាំងឡាយរបស់គំរោង។

**ភាតព្វកិច្ចក្នុងការគ្រប់គ្រងគំរោងមានដូចជា :**

- ការសង្កេត និងប៉ាន់ស្មាន
- ការបង្កើត និងធ្វើផែនការ
- ការរៀបចំចាត់ចែង និងផ្ទេរការងារ
- ការដោះស្រាយបញ្ហា និងធ្វើការសំរេចចិត្ត
- ការតាមដាន និងវាយតំលៃ

### ក. ការសង្កេត និងប៉ាន់ស្មាន

វាគឺជាតំរូវការដំបូងបង្អស់ សំរាប់ការដាក់អោយអនុវត្ត នៃគំរោងរបស់អង្គការ រឺក្រុម ។ មានន័យថា ជាការក្រឡេកមើលទៅខាងក្រៅដែននៃអង្គការ ថាតើមានអ្វីកំពុងកើតឡើងនៅជុំវិញខ្លួនខ្ញុំ ហើយតើខ្ញុំ ត្រូវឆ្លើយតបទៅនឹងអ្វីខ្លះ? នៅក្នុងដែនអង្គការ ថាតើមនុស្សកំពុងបំពេញការងារយ៉ាងដូចម្តេច ហើយតើយើងត្រូវការធ្វើអ្វី ដើម្បីអោយកាន់តែប្រសើរឡើង?

ដើម្បីធ្វើការងារបានល្អ វិធានការគឺត្រូវគិតនូវរាល់ជំហានពីមួយថ្ងៃទៅមួយថ្ងៃទាក់ទងនឹងការក្រឡេកមើលជុំវិញខ្លួន ការប្រមូលពតិមាន និងការឆ្លុះបញ្ចាំងនូវអ្វីដែលអ្នកបានឃើញ ។

## ខ. ការបង្កើត និងធ្វើផែនការ

ក្នុងនាមជាអ្នកគ្រប់គ្រង ជាញឹកញាប់អ្នកមានភារកិច្ចទទួលខុសត្រូវ ចំពោះការប្រែក្លាយការដឹកនាំតំរង់ទិសជារួម ទៅជាគំរោងជាក់លាក់ ដែលនឹងត្រូវអនុវត្តដោយអ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

## គ. ការរៀបចំចាត់ចែង និងផ្ទេរការងារ

ជាការចាប់ផ្តើម នៃផ្នែកជាក់ស្តែងជាច្រើន នៃដំណាក់កាលរៀបចំ ។ មុននឹងអ្នកអាចអនុវត្តផែនការមួយ អ្នកនឹងត្រូវរៀបចំធាតុលំអិតទាំងឡាយ នៃការអនុវត្តន៍ ដូចជាការបង្កើតប្រព័ន្ធសំរាប់ការរៀបចំថវិកា គណនេយ្យ ការផ្គត់ផ្គង់ និងការត្រួតពិនិត្យសំភារៈ ការធ្វើរបាយការណ៍ ។ល។ ការផ្ទេរការងារជាផ្នែកមួយក្នុងចំណោមផ្នែកដ៏លំបាកនៃការអនុវត្តន៏ការចាត់ចែងគំរោង ។ អ្នកគ្រប់គ្រងជាច្រើន បានយល់ឃើញថាវាមានការលំបាកច្រើននៅក្នុងការផ្ទេរការងារនេះ ហើយអ្នកគ្រប់គ្រងទាំងនោះចង់ធ្វើអ្វីដោយខ្លួនគេផ្ទាល់ ដែលនាំអោយគេមានការងារបន្ថែមទៀតយ៉ាងច្រើន ហើយទង្វើនេះមិនបានជួយជំរុញបុគ្គលិកពួកគេដើម្បីអោយអភិវឌ្ឍន៍ទៅមុខបានដែរ ។

## ឃ. ការដោះស្រាយបញ្ហា និងការធ្វើការសំរេចចិត្ត

ជាការពិត វាគឺជាអ្វីដែលបង្រួមពេលវេលារបស់អ្នកគ្រប់គ្រង។ សំរាប់ការងារទាំងពីរនេះ វាជាការចាំបាច់ក្នុងការធ្វើទំនាក់ទំនង និងសហប្រតិបត្តិការអោយមានប្រសិទ្ធិភាពជាមួយក្រុមគំរោង។ ទំនាក់ទំនង និងសហប្រតិបត្តិការល្អ ផ្តល់នូវមូលដ្ឋានគ្រឹះសំរាប់ការអនុវត្តន៏នូវការសំរេចចិត្ត ដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។ នៅពេលដោះស្រាយបញ្ហា ការទំនាក់ទំនង និងសហប្រតិបត្តិការល្អក៏មានសារៈសំខាន់ណាស់ដែរ ។

## ង. ការត្រួតពិនិត្យ និងវាយតំលៃ

គឺជាភារកិច្ច ដែលអ្នកគ្រប់គ្រងត្រូវធ្វើជាបន្តបន្ទាប់ ។ ជាទូទៅការត្រួតពិនិត្យ ត្រូវធ្វើឡើងចំពោះសកម្មភាពទាំងឡាយ ក៏ប៉ុន្តែវាក៏ធ្វើឡើងចំពោះហិរញ្ញវត្ថុ សំភារៈ និងឧបករណ៍ និងទង្វើរបស់មនុស្សនៅក្នុងក្រុមដែរ ។

អ្នកគ្រប់គ្រងគំរោង ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព ទៅលើ :

១. **ការងារ** : ដើម្បីអោយរាល់សកម្មភាពទាំងអស់ត្រូវបានសំរេចបានទៅតាមលំដាប់លំដោយ នៃគោលបំណង

២. **ធនធានមនុស្ស** : ដើម្បីអោយអ្នកដែលធ្វើការជាមួយនឹងគំរោងមានទិសដៅច្បាស់លាស់ និងការជំរុញលើកទឹកចិត្ត

៣. **ការទំនាក់ទំនង រឺការផ្តល់ដំណឹង :** ដើម្បីអោយបុគ្គលិកទាំងអស់ទទួលបានព័តិមានដែលគេត្រូវការ សំរាប់បំពេញការងាររបស់គេ

៤. **គុណភាព :** ដើម្បីធ្វើអោយគេយល់ដឹងច្បាស់លាស់ពីគោលបំណងរបស់គំរោង ដើម្បីធានាដល់គុណភាព នៃការអនុវត្តន៏

៥. **ពេលវេលា :** ដើម្បីអោយគំរោងបញ្ចប់ទៅតាមពេលវេលាកំណត់

៦. **ចំណាយ :** ដើម្បីអោយគំរោងត្រូវបានដំណើរការនៅក្នុងក្របខ័ណ្ឌនៃថវិកាដែលមាន ។

**លក្ខណៈមួយចំនួន សំរាប់អ្នកគ្រប់គ្រង :**

- មានកិរិតបច្ចេកទេសលើជំនាញ
- មានកិរិតខ្ពស់លើជំនាញ នៃការគ្រប់គ្រង
- មានទិសដៅឆ្ពោះទៅរកលទ្ធផល
- ជាអ្នករៀបចំចាត់ចែងដ៏ចំណាន
- មានភាពចាស់ទុំក្នុងការវិនិច្ឆ័យ
- មានការសារទរ ស៊ើចសរសើរ
- មានភាពជាអ្នកដឹកនាំ ជាពិសេសភាពជាអ្នកដឹកនាំក្រុម
- ត្រូវតែជាអ្នកពូកែខាងទំនាក់ទំនង
- មានជំនាញខាងចិត្តសាស្រ្តមនុស្ស
- មានភាពធន់ទ្រាំងនឹងភាពតានតឹង និងមានលទ្ធភាពដោះស្រាយបញ្ហាទាក់ទងនឹងភាពតានតឹង
- មានសមត្ថភាពខ្ពស់ក្នុងការដោះស្រាយ ប្រឈមមុខ នឹងបំរែបំរួលក្នុងការអនុវត្តន៏
- ចេះលើកទឹកចិត្តដល់បុគ្គលិក
- ជាអ្នកចរចារកិរិតខ្ពស់
- មានសមត្ថភាពពិនិត្យមើលលើចំនុចទាំងអស់របស់គំរោងសាំញ៉ាំ ។

## ៥. វដ្តគំរោង

មានអង្គការជាច្រើនបានអនុវត្តគំរោងមួយ រឺច្រើន។ គំរោងតូច រឺធំ តំលៃតិច រឺច្រើន ត្រូវបានដំណើរការអនុវត្ត ដោយយោងទៅតាមរយៈពេលវែង រឺ ខ្លី។ មានវិធីសាស្រ្តជាច្រើន ត្រូវបានកែលំអដើម្បីពណ៌នា និងពន្យល់ពីវដ្ត នៃ គំរោង ។

វដ្តគំរោង រួមផ្សំឡើងដោយបណ្តុំ នៃជំហានសំខាន់ៗ នៅក្នុងដំណើរការនៃការការចាប់ផ្តើមគំរោង, ការរៀបចំផែនការគំរោង, ការកែលំអ និងដាក់នៅក្នុងការធ្វើប្រតិបត្តិការផ្នែកបច្ចេកទេសរបស់គំរោង ។




### ៥.១ ការកំណត់អត្តសញ្ញាណ ( Identification )

នៅក្នុងវគ្គនេះ យើងត្រូវកំណត់អំពីគំនិត នៃគំរោងដោយផ្អែកទៅលើបញ្ហា រឺគំនិតជាក់លាក់ ។ ការកំណត់អត្តសញ្ញាណ គឺជាផ្នែកដ៏សំខាន់បំផុតក្នុងការចាប់ផ្តើមគំរោងអភិវឌ្ឍន៍មួយ ។ ពាក្យថា កំណត់អត្តសញ្ញាណ នៅពេលនេះមានន័យថាជាការផ្តើមគំនិតដើម្បីធ្វើអ្វីមួយ ដែលអាចជួយអោយមានភាពកាន់តែប្រសើរឡើងនូវសេដ្ឋកិច្ច រឺលក្ខ័ណ្ឌសង្គមរបស់មនុស្ស ។ គំនិតរបស់គំរោងមួយកើតចេញមកអំពីការងារដែលត្រូវបានអភិវឌ្ឍន៍ឆ្ពោះទៅការផ្តល់អ្វីមួយ ដើម្បីធ្វើអោយកាន់តែប្រសើរឡើងនូវលក្ខ័ណ្ឌ នៃការរស់នៅរបស់ប្រជាជន ។ គំនិតនៃគំរោងមិនបានដាក់កំរិតចំពោះតែអ្នកដែលជាប់ទាក់ទងទៅនឹងការងារអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែគឺទៅដល់ជនធម្មតាទាំងឡាយ ដែលរស់នៅក្នុងតំបន់ក្រីក្រ រឺភូមិមួយផងដែរ ដែលគេអាចមានគំនិតសមស្របមួយគ្រប់គ្រាន់ និងប្រែក្លាយទៅជាគំរោងមួយបាន។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកដែលមានចំណេះដឹង រឺពត៌មានជាក់លាក់អំពីលក្ខ័ណ្ឌ រឺស្ថានភាពខ្លះ អាចស្ថិតនៅក្នុងលំដាប់អ្នកដែលមានអត្ថប្រយោជន៏ដើម្បីកំណត់អត្តសញ្ញាណ នៃគំរោងមួយជាងអ្នកដទៃ ។

### ៥.២ ការវាយតំលៃពីភាពដែលអាចធ្វើទៅបាន ( Assessing the feasibility )

ក្រោយពេលដែលយើងបានកំណត់គំរោងមួយរួចហើយ និងប្រសិនបើការអង្កេតលើកដំបូងបង្ហាញថា វាគឺជាគំរោងល្អមួយ គេត្រូវធ្វើការសិក្សាលំអិតមួយដើម្បីពិនិត្យមើលថាតើគំរោងនេះអាចនឹងអនុវត្តទៅបានដែររឺទេ ហើយថា តើគំរោងដែលនឹងត្រូវអនុវត្តនេះ នឹងអាចសំរេចបាននូវក្តីសង្ឃឹមដែលគេរំពឹងទុកដែររឺទេ ។ នៅក្នុងវគ្គនេះ

គេត្រូវសិក្សាត្រួសៗទៅលើទិដ្ឋភាពមួយចំនួនធំ ដើម្បីអោយអាចដឹងច្បាស់ថាគំរោងមានតំលៃត្រូវអនុវត្ត រឺយ៉ាងណា។

### ៥.៣ ការរៀបចំសំណើរបស់គំរោង (Preparation of Project Proposal)

ប្រសិនបើការសិក្សាពីលទ្ធភាពដែលអាចធ្វើទៅបាន បង្ហាញថាគំរោងដែលត្រូវបានកំណត់ឡើងនេះសមស្របសំរាប់ការអនុវត្តន៍ នោះបន្ទាប់មកគេត្រូវរៀបចំសំណើររបស់គំរោង រឺឯកសាររបស់គំរោង ដែលផ្តល់នូវពតិមានសំខាន់ៗរបស់គំរោង ។ បន្ទាប់មកគេនឹងដាក់សំណើរនេះជូនទៅភ្នាក់ងារផ្តល់មូលនិធិដែលក្នុងនោះអាចជារដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ធនាគារ រឺភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ។

### ៥.៤ ការប៉ាន់ប្រមាណមើល និងអនុម័ត (Appraisal and Approval)

នៅក្នុងវគ្គនេះ សំណើររបស់គំរោង នឹងត្រូវបានភ្នាក់ងារផ្តល់មូលនិធិ ពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ដើម្បីធ្វើការសំរេចចិត្តថា តើគំរោងនេះសមស្របសំរាប់ការផ្តល់មូលនិធិអោយដែរឺអត់ ។ ប្រសិនបើភ្នាក់ងារផ្តល់មូលនិធិពេញចិត្តចំពោះគំរោងដែលស្នើឡើងនេះ ពួកគេនឹងអនុម័ត ហើយផ្តល់មូលនិធិសំរាប់ការអនុវត្តន៍គំរោង ។ នៅក្នុងករណីខ្លះ ភ្នាក់ងារផ្តល់មូលនិធិយល់ថាគំរោងដែលបានស្នើឡើង គឺជាគំនិតល្អមួយ ប៉ុន្តែទំរង់ នៃគំរោងដែលបានស្នើឡើង មិនមានការពន្យល់អោយបានក្បោះក្បាយគ្រប់គ្រាន់ ។ ក្នុងករណីនេះ ភ្នាក់ងារផ្តល់មូលនិធិអាចស្នើដល់អ្នករៀបចំគំរោងអោយធ្វើការកែលំអ រឺកែប្រែ។ នៅពេលកែលំអ រឺកែប្រែរួចហើយ ភ្នាក់ងារផ្តល់មូលនិធិនឹងពិចារណាឡើងវិញនូវគំរោងនេះ។ ប្រសិនបើភ្នាក់ងារផ្តល់មូលនិធិមិនពេញចិត្ត គេនឹងបដិសេធន៍នូវគំរោងសំណើរនេះ ។

### ៥.៥ ការអនុវត្តន៍គំរោង (Implementation)

នៅវគ្គនេះ គំរោងដែលទទួលបាននូវការអនុម័តដោយភ្នាក់ងារផ្តល់មូលនិធិ នឹងប្រែក្លាយទៅជាសកម្មភាពដោយការអនុវត្តន៍នូវសកម្មភាពទាំងឡាយ ដែលគេបានគ្រោងធ្វើនៅក្នុងគំរោង ។

### ៥.៦ ការត្រួតពិនិត្យ និងវាយតំលៃគំរោង (Monitoring and Evaluation)

ការត្រួតពិនិត្យ និងវាយតំលៃ គឺជាការសិក្សាមួយ ដែលធ្វើឡើងសំដៅពិនិត្យមើលថាតើគំរោងអាចសំរេចបាននូវគោលបំណងរបស់ខ្លួនដែរឺទេ តើគំរោងទទួលបានលទ្ធផលអ្វីខ្លះ តើអ្វីខ្លះដែលជាកំហុសឆ្គងរបស់គំរោង និងហេតុអ្វី ។ ហើយតើយើងអាចរៀនសូត្របានអ្វីខ្លះពីការអនុវត្តន៍គំរោង ដើម្បីកែលំអការធ្វើផែនការ និងការអនុវត្តន៍នូវគំរោងមួយ ដែលស្រដៀងគ្នានេះនាពេលអនាគត ។

# ការធ្វើផែនការគំរោង
# Project Planning

ការធ្វើផែនការ គឺជាការរៀបចំយ៉ាងត្រឹមត្រូវច្បាស់លាស់សព្វគ្រប់ នូវសកម្មភាពទាំងឡាយ ដើម្បីសំរេចគោលបំណងមួយ រឺច្រើន ។ ការធ្វើផែនការផ្តល់នូវសារៈសំខាន់ ដូចតទៅ :

- ផ្តល់នូវទិសដៅ (Give a direction) : ជាចំណុចសំខាន់
- សំរបសំរួល (Coordinates) : ភ្ជាប់រាល់ការប្រឹងប្រែងទាំងអស់
- ផ្តល់នូវខ្នាតគំរូ (Provide Standard) : ទំហំ នៃការប្រតិបត្តិការងារ
- បញ្ជាក់ (Clarifies) : ផ្តល់នូវភាពច្បាស់លាស់ នៃគោលបំណង សកម្មភាព និងធនធាន
- រៀបចំ (Prepares) : ផ្តល់ដល់យើងនូវឧបករណ៍ សំរាប់ប្រឈមមុខនឹងបញ្ហា
- ជំរុញ (Stimulartes) : លើកទឹកចិត្តអោយទទួលជ័យជំនះ ។

☛ **លក្ខណៈ នៃផែនការដែលល្អ គឺផែនការនោះ ត្រូវតែ :**

- សមស្របទាំងនយោបាយ (អង្គការ, អង្គភាព ស្ថាប័ន), ការស្រាវជ្រាវ, បទពិសោធន៍, បញ្ហាដែលកំណត់ និងតំរូវការ
- មានគោលបំណងច្បាស់លាស់
- អាចអនុវត្តបាន (ធនធាន មនុស្ស ថវិកា សំភារៈ ពេលវេលា) ។

ដើម្បីធ្វើផែនការអោយបានល្អ ត្រូវមានទិន្ន័យច្បាស់លាស់ ទស្សនៈ និងបេសកកម្មច្បាស់លាស់ ការចូលរួម និងលទ្ធភាព ។

គេអាធ្វើផែនការតាមរបៀបផ្សេងៗជាច្រើន តែរបៀបដែលគេនិយមប្រើប្រាស់នោះ គឺការធ្វើផែនការដោយផ្តោតលើគោលបំណង Objective Oriented Project Planning (OOPP) ។ ចំពោះការធ្វើផែនការគំរោង ដែលផ្តោតទៅលើគោលបំណង មានការប្រើប្រាស់ពាក្យផ្សេងៗពីគ្នា ដោយយោលទៅតាមអ្នកអនុវត្ត គឺ :

- GOPP: Goal Oriented Project Planning
- LFA: Logical Framework Approach
- ZOPP: មកពីពាក្យអាល្លឺម៉ង់ ដែលមានន័យថា :

| | |
|---|---|
| + Ziel: | Objective |
| + Orientierte: | Oriented |
| + Projekt: | Project |
| + Planung: | Planning |

- OOPP: Objective Oriented Project Planning

វិធីធ្វើផែនការគំរោងដែលផ្តោតទៅលើគោលបំណង (OOPP) គឺត្រូវបានផ្អែកលើគំនិត ដែលមានឈ្មោះថា Logical Framework ហើយដែលត្រូវបានបង្កើតឡើងដោយទីប្រឹក្សា USAID ពីររូប ។ វិធីនេះ ត្រូវបានបង្ហាញទៅដល់អង្គការកិច្ចសហប្រតិបត្តិការ បច្ចេកទេស ថវិការបស់ប្រទេសអាល្លឺម៉ង់ (GTZ) នៅដើមឆ្នាំ ១៩៨៣ ។ វិធីធ្វើផែនការគំរោងកម្មវិធី ដែលផ្តោតលើគោលបំណងនេះ ត្រូវបានដាក់អោយប្រើប្រាស់នៅក្នុងការរៀបចំ និងអនុវត្តរាល់គំរោងទាំងអស់ នៃផែនការពីគំរោងអភិវឌ្ឍន៍ធំៗ រហូតដល់គំរោងផ្ទាល់ខ្លួនតូចៗនៅតាមផ្ទះផងដែរ ។

**ក. គុណសម្បត្តិ នៃការប្រើប្រាស់ OOPP មានដូចតទៅ :**

- វាធ្វើអោយប្រាកដថាសំណួរសំខាន់ៗ ត្រូវមានគេសួរ ហើយភាពអសកម្មត្រូវបានគេវិភាគ ដើម្បីផ្តល់ពតិមានល្អៗ ដែលទាក់ទងដល់អ្នកសំរេចចិត្ត
- វាណែនាំនូវការធ្វើវិភាគសមហេតុផល និងតាមលក្ខណៈជាប្រព័ន្ធ នៃធាតុសំខាន់ៗ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ដែលបង្កើតអោយការរៀបចំគំរោងបានល្អ
- វាធ្វើអោយប្រសើរឡើងនូវការធ្វើផែនការ ដោយលើកឡើងជាគោលសំខាន់នូវទំនាក់ទំនងរវាងធាតុផ្សេងៗ នៃគំរោង និងបណ្តាកត្តាខាងក្រៅ
- វាផ្តល់អោយនូវមូលដ្ឋានដ៏ល្អមួយ សំរាប់ការត្រួតពិនិត្យដែលមានលក្ខណៈជាប្រព័ន្ធ និងការវិភាគពីឥទ្ធិពលរបស់គំរោង
- វាសំរួលការយល់ដឹងទូទៅ និងការទំនាក់ទំនងគ្នាដ៏ល្អរវាងអ្នកសំរេចចិត្ត អ្នកគ្រប់គ្រង និងភាគីផ្សេងៗ ដែលជាប់ទាក់ទងក្នុងគំរោង
- ការរៀបចំ និងការគ្រប់គ្រង ទទួលប្រយោជន៍ពីទំរង់ការសំរួលសំរាប់ការប្រមូល និងការប៉ាន់ស្មានមើលពតិមាន
- ការប្រើប្រាស់ OOPP និងការត្រួតពិនិត្យដែលមានលក្ខណៈជាប្រព័ន្ធ អាចធានារបៀបដោះស្រាយអោយដំណើរការប្រព្រឹត្តិទៅបានជាធម្មតានៅពេលដែលបុគ្គលិកចាស់ត្រូវបានផ្លាស់ប្តូរ
- មានស្ថាប័នជាច្រើន បានយកគំនិត OOPP មកប្រើ វាអាចសំរបសំរួលនូវការទំនាក់ទំនងរវាងរដ្ឋាភិបាល និងបណ្តាភ្នាក់ងារផ្តល់ជំនួយ ។
- ការប្រើប្រាស់ដ៏ទូលំទូលាយ នៃទំរង់ OOPP វាធ្វើអោយងាយស្រួលទទួលរ៉ាប់រង ទាំងការសិក្សាតាមផ្នែកៗ និងការសិក្សារបៀបប្រៀបធៀបជាទូទៅ ។

**ខ. គុណវិបត្តិនៃការប្រើប្រាស់ OOPP មានដូចតទៅ :**

- ភាពមិនប្រែប្រួលនៅក្នុងការរៀបចំគំរោងកម្មវិធី អាចកើតមានឡើងនៅពេលដែលគោលបំណង និងកត្តាផ្នែកខាងក្រៅ ត្រូវបានគេសង្កត់ធ្ងន់ ។ យើងអាចជៀសវាងវា ដោយពិនិត្យគំរោងឡើងវិញអោយបានទៀងទាត់ ដែលធាតុសំខាន់ៗទាំងអស់អាចត្រូវបានវាយតំលៃឡើងវិញ និងធ្វើការកែប្រែ ។
- OOPP គឺជាឧបករណ៍សំរាប់ធ្វើការវិភាគជាទូទៅ វាមិនលំអៀងទៅនឹងបញ្ហា នៃការចែកប្រាក់ចំណូល ឱកាស នៃការចូលបំរើការងារ ការប៉ាន់ស្មានទៅលើធនធាន ការចូលរួមថ្នាក់មូលដ្ឋាន តំលៃ និងលទ្ធភាព នៃយុទ្ធសាស្ត្រ និងបច្ចេវិជ្ជា រឺឥទ្ធិពលទៅលើបរិស្ថាន ។
- ដូចនេះ OOPP គឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍នានា ដែលត្រូវបានប្រើប្រាស់នៅពេលរៀបចំអនុវត្ត និងវាយតំលៃគំរោងកម្មវិធី ហើយវាមិនអាចជំនួសការធ្វើវិភាគក្រុមគោលដៅខាងការវិភាគពីចំណូលចំណាយ ការធ្វើផែនការពីពេលវេលា ការធ្វើវិភាគពីឥទ្ធិពលទៅមុខ ។ល។ ទេ។
- ផលប្រយោជន៍ពេញលេញ នៃការប្រើប្រាស់ OOPP អាចទទួលបានតែតាមរយៈការបណ្តុះបណ្តាល ដែលមានលក្ខណៈជាប្រព័ន្ធ នៃភាគីទាំងអស់ដែលជាប់ទាក់ទង និងធ្វើបន្តពីវិធីសាស្ត្រនោះ ។

## ១. ការធ្វើផែនការជាមួយ OOPP

មុននឹងឈានចូលដល់ជំហាន នៃការធ្វើផែនការជាផ្លូវការ វាជាការសំខាន់ណាស់ក្នុងការយល់ដឹងអោយបានល្អិតទៅលើធាតុជាមូលដ្ឋានខ្លះៗ នៃវិធីសាស្ត្រធ្វើផែនការ។ បណ្តាធាតុទាំងនោះ គឺការចូលរួមវិធីសាស្ត្រជាក្រុម ការសំរបសំរួល ។ ការឯកភាពគ្នារបស់ក្រុមអ្នកធ្វើផែនការទៅលើបញ្ហាផ្សេងៗដែលកើតមានឡើង លទ្ធផលរបស់វា គឺជាផែនការដ៏ខ្លាំង និងជាការអនុវត្តន៍គំរោងកម្មវិធីដ៏ងាយស្រួល ។

- **ការចូលរួម :** ការប្រើ OOPP ផែនការនៃគំរោងកម្មវិធី ត្រូវបានរៀបចំឡើងដោយក្រុមអ្នកធ្វើផែនការ វាជាការសំខាន់ណាស់ចំពោះអ្នករៀបចំសិក្ខាសាលានាំមកនូវក្រុម នៃបណ្តាបុគ្គលដែលតំណាងអោយទស្សនៈផ្សេងៗគ្នា ដែលទាក់ទងទៅនឹងគំរោងកម្មវិធី ។ អ្នកដែលនឹងអនុវត្តផែនការពិតប្រាកដ ដែលត្រូវធ្វើនោះត្រូវតែមានវត្តមាន ។ បណ្តាអ្នកសំរេចចិត្តទាំងអស់ត្រូវតែចូលរួមនៅក្នុងសិក្ខាសាលា រឺបើសិនជាមិនអាចទេ គេត្រូវសង្ខេបអោយអ្នកទាំងនោះដឹងនៅមុនពេល រឺក្រោយពេលដំណើរការធ្វើផែនការ។ សមាជិក នៃក្រុមអ្នកទទួលផល រឺអ្នកតំណាងដែលសមស្រប គួរតែមានវត្តមាននៅក្នុងសិក្ខាសាលា។ បើសិនជាគំរោងកម្មវិធីនោះ ជាផ្នែកមួយនៃកម្មវិធីជំនួយទ្វេភាគី នោះភាគីទាំងសងខាងគួរតែមានតំណាងនៅក្នុងសិក្ខាសាលា នៃការធ្វើផែនការនោះ ដោយបុគ្គលិកគំរោងកម្មវិធី និងទីប្រឹក្សា។
- **វិធីសាស្ត្រជាក្រុម :** មនុស្ស ដែលរៀបរាប់ខាងលើ គឺបង្កើតជាក្រុម ។ គេទាំងនោះ អាចជាក្រុមគ្រប់គ្រងដែលរួមមានអ្នកទទួលផល ដែលសកម្មភាពនៃគំរោងកម្មវិធីនោះមានឥទ្ធិពលទៅលើ។ ក្រុមនេះជួបជាមួយគ្នានៅ

លើមូលដ្ឋានជាក់លាក់មួយ ។ គេចូលរួមក្នុងការសំរេចចិត្តទាំងលើយុទ្ធវិធី និងការអនុវត្តន៍ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលសិក្ខាសាលាធ្វើផែនការ ។ គេដឹកនាំការសំរេចចិត្តជាក្រុម ដោយមិនមានលំអៀងទៅខាងណាមួយ ។

- **ការសំរបសំរួល :** ដើម្បីអោយមានប្រសិទ្ធិភាពខ្ពស់ ដំណើរការធ្វើផែនការតាម OOPP ត្រូវតែគ្រប់គ្រង រឺសំរបសំរួលដោយអ្នកសំរបសំរួលដ៏មានបទពិសោធន៍មួយ ។ សមាជិក នៃក្រុមធ្វើផែនការត្រូវតែអាចផ្តល់ការយកចិត្តទុកដាក់របស់គេទៅនឹងការពិភាក្សា និងធ្វើសេចក្តីសំរេចចិត្តដែលកើតមានឡើងនៅក្នុងជំហានីមួយៗ នៃដំណើរការធ្វើផែនការ ។

សិក្ខាសាលាមួយស្តីពី OOPP ផ្តោតទៅលើចំនុចគន្លឹះនៃស្ថានភាពស្មុគ្រស្មាញដែលមានស្រាប់នៅក្នុងស្ថាប័នអង្គភាព រឺប្រទេសជាដៃគូ ។ ភាពទូលំទូលាយ នៃការធ្វើផែនការ នឹងត្រូវបានកំណត់ដោយ :

- ចំនួនពតិមានមានអាចរកបាន
- ភាពស្មុគ្រស្មាញ នៃបញ្ហាដែលត្រូវរកផ្លូវដោះស្រាយ
- ចំនួន និងសមត្ថភាពរបស់អ្នកចូលរួម ។

ចំនុចចេញដំណើរសំរាប់សិក្ខាសាលា OOPP គួរតែជាក្រដាសមួយសន្លឹក ដែលពិពណ៌នាពីបញ្ហាបច្ចុប្បន្នក្នុងតំបន់គំរោងកម្មវិធី ។ ឧទាហរណ៍ ការសិក្សាពីលទ្ធភាព រឺក៏ពតិមានដែលត្រូវប្រមូលយ៉ាងពិសេសសំរាប់គោលបំណងនេះ។ ពតិមានបែបនេះ គួរតែអាចរកបានសំរាប់អោយអ្នកចូលរួមបានអានមុនពេលរៀបចំសិក្ខាសាលា។ ពតិមានដែលមានទំនាក់ទំនងស្តីពីក្រុមដែលបានប្រយោជន៍ សេចក្តីត្រូវការរបស់ខ្លួន ស្ថានភាពវប្បធម៌សង្គម ។ល។ ក៏គួរតែរកអោយបានដែរ ។ ខាងក្រោមនេះ គឺជាជំហានផ្សេងៗនៅក្នុងការធ្វើផែនការ :

**ការវិភាគពីស្ថានភាព (Analyzing the Situation)**

- ការវិភាគពីការចូលរួម
- ការវិភាគពីបញ្ហា
- ការវិភាគពីគោលបំណង
- ការវិភាគពីវិធីសាស្រ្តដោះស្រាយនានា

**ការរៀបចំគំរោង ( Designing Project )**

- ធាតុ នៃគំរោង
- កត្តាខាងក្រៅ
- សន្ទស្សន៍ ។

# ការវិភាគពីស្ថានភាព
# Analyzing the situation

ការវិភាគពីស្ថានភាពទូទៅ គឺជាជំហានដំបូងគេបង្អស់ នៅក្នុងការធ្វើផែនការអភិវឌ្ឍន៍អោយបានសមស្រប ។ ដោយសាររបាយការណ៍ នៃផែនការអភិវឌ្ឍន៍ទាំងនេះ នឹងត្រូវបានរៀបរៀងឡើងជាមួយនឹងការវិភាគដ៏ទូលំទូលាយ និងដែលអាចងាយយល់ លទ្ធផលនៃការវិភាគនេះ នឹងអាចជួយអោយគេអាចផ្តួចផ្តើមគំនិត នៃគំរោងបាន ។ ឧទាហរណ៍ គំរោងផ្គត់ផ្គង់ទឹក អាចផុសចេញឡើងដើម្បីដោះស្រាយបញ្ហាកង្វះខាតទឹក។ ប្រសិនបើមានភាពអត់ការងារធ្វើច្រើន វាអាចនាំអោយមានការកំណត់អត្តសញ្ញាណរបស់គំរោង ដើម្បីបង្កើតជាឱកាសការងារអោយបានច្រើនឡើង ។

## ១. ការវិភាគពីការចូលរួម

ការខ្វះខាត នៃចំណេះដឹងក្នុងចំណោមអ្នកធ្វើផែនការអភិវឌ្ឍន៍ ទាំងខាងអ្នកផ្តល់ជំនួយ ទាំងខាងភាគីដៃគូ អំពីមនុស្សដែលគំរោងអភិវឌ្ឍន៍មានឥទ្ធិពលទៅលើ បានបង្ហាញពីបុព្វហេតុរួម នៃបញ្ហាគំរោង ដូចដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ដែលវាយតំលៃ និងការសិក្សានានាយ៉ាងច្រើន ។

ដូច្នេះនៅក្នុងដំណាក់កាលទីមួយនេះ ស្ថានភាពទូទៅរបស់ក្រុមដែលអាចមានផលប្រយោជន៍ និងបុគ្គលម្នាក់ៗ ហើយនឹងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធ យើងត្រូវកំណត់អោយបានច្បាស់ ។

**នំរង់ការ :**

- សរសេរដោយមិនបាច់គិតពីលំដាប់លំដោយ រាប់ឈ្មោះទាំងអស់របស់ក្រុមទទួលផល ស្ថាប័ន រឺអង្គភាពគំរោង ។ល។ ដែលស្ថិតនៅជិតក្នុងតំបន់ដែលបង្កអោយមានបញ្ហា រឺទទួលឥទ្ធិពលដោយបញ្ហានេះ។ បង្ហាញពីឥទ្ធិពលខាងក្រៅ រឺផលប្រយោជន៍នៃការចូលរួមផ្សេងៗ ។
- ធ្វើការវិភាគក្រុម រឺមនុស្សដែលបានរៀបរាប់នោះ ថាតើគេមានលក្ខណៈដូចគ្នា រឺខុសគ្នាទៅតាមបញ្ហា រឺផលប្រយោជន៍ ហើយត្រូវកំណត់ និងដាក់វាអោយដាច់ពីគ្នា ។
- ក្រុមធ្វើផែនការ ត្រូវសំរេចទៅលើលក្ខណៈវិនិច្ឆ័យ សំរាប់ការវិភាគក្រុម ស្ថាប័ន រឺអង្គភាពទាំងអស់នោះ
- នៅពេលបែងចែកវាជាក្រុម ត្រូវធ្វើទៅតាមជំហានក្នុងលំដាប់ដូចតទៅ : ប្រមូល ចាត់ថ្នាក់ បង្ហាញ វិភាគ និងវាយតំលៃ ។
- បែងចែកក្រុម និងស្ថាប័ន រឺអង្គភាព ដែលទទួលផលចេញជាពីរ គឺអ្នកចូលរួម និងអ្នកមិនចូលរួម
- ក្រុមអ្នកធ្វើផែនការ ពិភាក្សាថាតើផលប្រយោជន៍ និងទិដ្ឋភាពអ្វីខ្លះ ដែលត្រូវផ្តល់អាទិភាពជាងគេ នៅពេលវិភាគបញ្ហា ។

- ការវិភាគស៊ីជំរៅ ហើយដាច់ពីគ្នា អាចធ្វើឡើងពីស្ថានភាពខាងក្នុងស្ថាប័ន រឺក្រុមទទួលផល និងទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ។

## ២. ការវិភាគពីបញ្ហា

ជាទូទៅរបាយការណ៏អង្កេតលើកដំបូង ផ្តល់នូវចំនុចសំខាន់ៗ នៃបញ្ហាដែលមានស្រាប់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គេក៏លើកឡើងផងដែរនូវបញ្ហាដែលអាចកើតមានឡើងនៅពេលអនាគត រឺក៏ឆ្លុះបញ្ចាំងនូវនិន្នាការដែលកាន់តែខ្លាំងឡើងៗរបស់បញ្ហា ។ ឧទាហរណ៏ បើរបាយការណ៏បញ្ជាក់ថាទឹកធម្មជាតិចេញពីក្រោមដី កំពុងរីងស្ងួតបន្តិចម្តងៗ វាអាចនាំទៅដល់ការកំណត់ឡើងនូវគំរោងផ្គត់ផ្គង់ទឹក រឺគំរោងបញ្ចូលទឹកក្នុងស្រែ ។ ដូចគ្នានេះដែរ បើសិនជាមានផែនការសាងសង់រចនាសម្ព័ន្ធទប់ទឹកមិនអោយហូរចេញ វាអាចលេចចេញនូវការលើកឡើងនូវគំរោងលើការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋពីភូមិដែលទទួលរងនូវទឹកជំនន់ ។

នៅពីលើមូលដ្ឋានពត៌មានដែលរកបាន ស្ថានភាពដែលមានស្រាប់ត្រូវបានវិភាគ ពោលគឺបញ្ហាសំខាន់ៗ ត្រូវបានកំណត់ ហើយការទាក់ទងគ្នាសំខាន់ៗ រវាងបញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុងដើមឈើបញ្ហា ។

វាជាការសំខាន់ណាស់ ដែលការជ្រើសរើសទាំងអស់ នៅតែបើកចំហរនៅពេលធ្វើការវិភាគបញ្ហា ។ គោលបំណងនៅដំណាក់កាលដំបូង គឺដើម្បីបង្កើននូវទស្សនៈទូទៅស្តីពីស្ថានភាព ក្រោយមកទៀតនៅក្នុងដំណើរការ នឹងត្រូវបានធ្វើអោយតូច និងស៊ីជំរៅ ដើម្បីរៀបចំគំរោង ។

**ការបង្កើតបញ្ហាត្រូវ :**

- កំណត់បញ្ហាដែលមានស្រាប់ ដែលមិនអាចធ្វើបាន បញ្ហាដែលស្រមើស្រម៉ៃ រឺបញ្ហាអនាគត
- បញ្ហាមិនមែនអវត្តមាន នៃដំណោះស្រាយនោះទេ ក៏ប៉ុន្តែវាជាលក្ខណៈអវិជ្ជមាន ដែលមានក្នុងសភាពជាក់ស្តែង ។

**នីតិវិធី :**

- ដំបូង សមាជិកនៃក្រុមធ្វើផែនការម្នាក់ៗ ត្រូវសរសេរបញ្ហាមួយ ដែលគេយល់ថាជាបញ្ហាចំបង
- ភស្តុតាង ដែលសង្ខេបមួយត្រូវបានផ្តល់ សំរាប់ការស្នើឡើង នៃបញ្ហាចំបងនីមួយៗ ។ ភស្តុតាងនោះ ជានិច្ច-កាល ជាផលប្រយោជន៏ និងជាបញ្ហារបស់មនុស្ស ក្រុម និងស្ថាប័នដែលចូលរួម ។
- បើសិនជានៅតែមិនទទួលបានការយល់ព្រមនោះ បន្ទាប់មកត្រូវ :
  - o រៀបចំបញ្ហាចំបងដែលស្នើឡើងនោះ ពីលើក្រោមគ្នាទៅតាមបុព្វហេតុ និងលទ្ធផលរបស់វា
  - o សាកល្បងម្តងទៀត ដើម្បីអោយមានការយល់ព្រមនៅលើបញ្ហាចំបង
- បើសិនជាមិនទទួលបានមតិថ្មីស្របគ្នាទៀតនោះ ត្រូវ :
  - o សាកល្បងធ្វើការចរចាររកគំនិតថ្មី ការសំដែងជាល្បែង រឺរបៀបសំរេចចិត្តផ្សេងៗទៀត

- o ជ្រើសរើសការសំរេចចិត្តដែលល្អបំផុត ឧទាហរណ៍ ដោយចាប់ផ្តើមពីចំណុចទូទៅមួយ ដើម្បីកំណត់ដំណោះស្រាយដែលគេចង់បាន ។ល។
- o រឺក៏សំរេចជាបណ្តោះអាសន្នលើបញ្ហាចំបងមួយ រឺពីរ ហើយចាប់ផ្តើធ្វើការងារបន្ត ប៉ុន្តែត្រូវត្រឡប់មកពិភាក្សាលើបញ្ហាចំបងវិញ ។

- ដើម្បីរៀបចំជំហានទៅមុខទៀត ការវិភាគបុព្វហេតុ នៃលទ្ធផល នៃបញ្ហាចំបង ជាការងាយស្រួល គឺសរសេរបណ្តាបញ្ហាសំរាប់ស្ថាប័ន និងក្រុមទទួលផលនីមួយៗ។ បណ្តាបញ្ហាដែលរៀបរាប់ជាមុនអោយអ្នកឯកទេស រឺក្នុងអំឡុងពេលសិក្ខាសាលាស្តីពី OOPP ដោយបណ្តាក្រុមតូចៗ។ ធ្វើដូច្នេះវាអាចធានាថាបន្ទាប់មក គេនឹងអាចពិភាក្សា និងរៀបចំដើមឈើបញ្ហាចំបងនោះ ។
- បុព្វហេតុដែលផ្ទាល់ និងត្រឹមត្រូវ នៃបញ្ហាចំបង ត្រូវដាក់អោយស្របគ្នា នៅពីខាងក្រោមនៃបញ្ហាចំបង
- ឥទ្ធិពលដែលផ្ទាល់ និងត្រឹមត្រូវ នៃបញ្ហាចំបង ត្រូវដាក់អោយស្របហើយនៅពីខាងលើ នៃបញ្ហាចំបង
- បុព្វហេតុ នៃឥទ្ធិពល ត្រូវបានវិភាគជាបន្តទៀត ទៅតាមគោលការណ៍ដូចខាងលើ ដូច្នេះទំនាក់ទំនងមែកធាងនៃបុព្វហេតុ និងឥទ្ធិពលនោះត្រូវបានបង្កើតបន្តទៀត ។

## ៣. ការវិភាគគោលបំណង

នៅក្នុងការវិភាគពីគោលបំណង ដើមឈើបញ្ហា ត្រូវបានបំលែងអោយទៅជាដើមឈើគោលបំណង នឹងត្រូវបានធ្វើការវិភាគ ។

**នីតិវិធី :**

- ដោយមើលពីលើចុះក្រោម បំលែងបណ្តាបញ្ហាទាំងនោះ ទៅជាគោលបំណង
  - o បញ្ហាជាពាក្យសរសេរដែលមានលក្ខណៈអវិជ្ជមាននោះ ត្រូវសរសេរវាអោយទៅលក្ខណៈវិជ្ជមានសំរាប់ទទួលបាននៅពេលអនាគត
  - o បញ្ហាចំបង ក៏ត្រូវបំលែងទៅជាគោលបំណងដូចបញ្ហាដទៃទៀតដែរ
- ចំណុច ដែលត្រូវពិនិត្យមើលនៅពេលបំលែង ពីបញ្ហាទៅជាគោលបំណងមានដូចខាងក្រោម :
  - o បញ្ជាក់ថា ទំនាក់ទំនងរវាងបុព្វហេតុ និងឥទ្ធិពលអាចក្លាយទៅជាមធ្យោបាយដើម្បីទទួលជោគជ័យទៅតាមលំដាប់លំដោយរបស់វា
  - o ដើមឈើគោលបំណង គួរតែសរសេរដាច់ដោយឡែក ។

## ៤. ការវិភាគរកវិធីសាស្ត្រដោះស្រាយនានា

គោលបំណង នៃការវិភាគរកវិធីសាស្ត្រដោះស្រាយនានា គឺដើម្បីកំណត់វិធីសាស្ត្រ ដែលអាចធ្វើបានការប៉ាន់ស្មានមើលពីលទ្ធភាពរបស់វា និងយល់ស្របលើយុទ្ធសាស្ត្រ នៃគំរោងរួមមួយ ។

សាខា នៃមធ្យោបាយ និងលទ្ធផលដែលអាចប្រព្រឹត្តិទៅបាននៅក្នុងដើមឈើគោលបំណង ដែលអាចក្លាយជាគំរោង ត្រូវបានកំណត់ និងគូសរង្វង់ជុំវិញ ។ សាខាទាំងអស់នេះរួមគ្នា បានជាវិធីសាស្ត្រដោះស្រាយបញ្ហា ។

**នំរង់ការ :**

- មែកធាងផ្សេងៗ នៃមធ្យោបាយ ដែលធ្វើអោយសំរេចនៅក្នុងដើមឈើគោលបំណង ត្រូវបានកំណត់ (គូសរង្វង់ដោយខ្មៅដៃនៅជុំវិញបណ្តាមែកធាងទាំងនោះ) ។ បណ្តុំមែកធាងនោះ អាចបង្កើតជាដំណោះស្រាយ ។
- បណ្តាដំណោះស្រាយទាំងនោះ ត្រូវបានកត់សំគាល់ដោយដាក់ថា វិធីដោះស្រាយផ្សេងៗ ដូចជាវិធីដោះស្រាយតាមផលិតកម្ម ការបង្កើនប្រាក់ចំណូល ការបណ្តុះបណ្តាល ។ល។
- លក្ខណៈវិនិច្ឆ័យសំខាន់ៗនៅពេលវាយតំលៃ និងជ្រើសរើសវិធីដោះស្រាយ គឺត្រូវតែសមស្រប និងមានលក្ខណៈពិតប្រាកដ ។ លក្ខណៈវិនិច្ឆ័យសំខាន់ៗរួមមាន :
  - o តំលៃសរុបរបស់គំរោង
  - o ផលប្រយោជន៍ចំពោះក្រុមគោលដៅ
  - o ឱកាសទទួលបានជោគជ័យរបស់គំរោង
  - o ប្រសិទ្ធិភាពក្នុងការដោះស្រាយបញ្ហា
  - o បច្ចេកទេស : ភាពសមស្រប ប្រើប្រាស់ធនធានក្នុងស្រុក ទីផ្សារអាចរកបាន
  - o ហិរញ្ញវត្ថុ : តំលៃ ភាពមាននិរន្តរភាពរបស់ហិរញ្ញវត្ថុ
  - o គ្រឹះស្ថាន ស្ថាប័នៈ សមត្ថភាព
  - o បរិស្ថាន : ឥទ្ធិពលលើបរិស្ថាន តំលៃបរិស្ថានធៀបនឹងផលប្រយោជន៍ ។

# ការរៀបចំបង្កើតគំរោង
# Designing the Project

## ១. Logical Framework (Log Frame)

**Logical Framework** គឺជាបណ្តុំគំនិតទាក់ទងគ្នា ដែលបង្ហាញនៅក្នុងវិធីប្រតិបត្តិមួយជាទំរង់ម៉ាទ្រិច (Matrix Form) ដែលជាលក្ខណៈយ៉ាងសំខាន់ នៃការប្រតិបត្តិ ។ វាផ្តល់នូវរបៀបពិនិត្យមើលថា តើការប្រតិបត្តិត្រូវបានរៀបចំល្អដែរ រឺទេ ។ ហើយម្យ៉ាងទៀត វានឹងជួយសំរួលដល់ការត្រួតពិនិត្យ និងវាយតំលៃផងដែរ ។

| Intervention Logic | ការអធិប្បាយ<br>Description | សន្ទស្សន៍<br>Indicator | មធ្យោបាយផ្ទៀងផ្ទាត់<br>Means of Verification | ការសន្មត់ជាមុន<br>Assumption |
|---|---|---|---|---|
| គោលបំណងរួម<br>Overall Objective | | | | |
| គោលបំណងរបស់គំរោង<br>Immediate Objective | | | | |
| លទ្ធផល<br>Outputs | | | | |
| សកម្មភាព<br>និងពេលវេលា<br>Acitivities and Timelines | | | | |
| Inputs | | | | |

Logical Framework គឺជាវិធីមួយ នៃការបង្ហាញពីការអនុវត្តន៍ ។ គោលបំណងរួម គោលបំណងរបស់គំរោង លទ្ធផល សកម្មភាព និងពេលវេលា Inputs និងទំនាក់ទំនងផ្សេងៗទៀតរបស់វា ត្រូវបានបង្ហាញ ជាលក្ខណៈប្រព័ន្ធដែលត្រឹមត្រូវ ។ ការបង្កើតLogcial Framework អាចប្រព្រឹត្តិទៅបានលុះត្រាតែមានការវិភាគពតិមានដែលអាចរកបាននោះអោយបានល្អ ( បញ្ហា គោលបំណង និងលទ្ធភាព រឺឱកាស) ។

ជាបន្ថែមលើទំនាក់ទំនងដែលសមហេតុផល រវាងគោលបំណងរួម គោលបំណងនៃគំរោង សកម្មភាព លទ្ធផល និង Inputs នៅមានកត្តាផ្នែកខាងក្រៅដែលមានឥទ្ធិពលទៅលើគំរោង ហើយកត្តាខាងក្រៅនេះ ក៏អាចបញ្ចូលទៅក្នុង Logical Framework ផងដែរ ។

គោលបំណងរួម គោលបំណងនៃគំរោង និងលទ្ធផល ត្រូវបានបង្ហាញដោយសន្ទស្សន៍ និងមធ្យោបាយផ្ទៀងផ្ទាត់ ដើម្បីទទួលបាននូវពតិមានដែលអាចវាស់វែងបាន ។ មធ្យោបាយ និងតំលៃត្រូវបានគេលំអិតនៅជួរផ្នែកខាងក្រោម (Inputs) ។

តារាងម៉ាទ្រិច គឺជាតារាងសង្ខេប ងាយស្រួលប្រើ និងធ្វើរបាយាការណ៍ កាត់បន្ថយបន្ទុកការងារចំពោះដំណាក់កាលផ្សេងៗនៃវដ្តគំរោង ។

Logcial Framework អាចត្រូវបានរៀបចំ និងបង្ហាញដោយសិក្ខាសាលាពីការរៀបចំគំរោង ។ វាក៏ជួយពិភាក្សាពីទំរង់ផ្សេងៗជាមុន និងនៅអំឡុងពេលអនុវត្តគំរោង ជាពិសេសគឺនៅពេលបង្ហាញក្នុងទំរង់ជាដ្យាក្រាមដោយប្រើ Card នៅលើជញ្ជាំង ។

ដូច្នេះ វាជាឧបករណ៍មួយសំរាប់ការយល់ដឹង និងបង្ហាញពីគោលបំណង នៃគំរោង យុទ្ធសាស្រ្ត ដែលអាចសំរេចបាន និងមធ្យោបាយផ្សេងៗត្រូវប្រើ ។ Logical Framework នេះ ត្រូវបានប្រើប្រាស់ដូចជាចំនុចយោងមួយនៅពេលធ្វើការត្រួតពិនិត្យ និងវាយតំលៃ ដើម្បីវិភាគលើលទ្ធផល នៃការអនុវត្តន៍ និងឥទ្ធិពលយូរអង្វែងរបស់គំរោង

## ២. ធាតុនៅក្នុង (Logical Framwork)

### - គោលបំណងរួម (Overal Objective)

គោលបំណងរួមនេះ មានលក្ខណៈទូលំទូលាយ និងមានទំហំធំជាងគំរោងទៅទៀត ដែលត្រូវប្រើប្រាស់រយៈពេលវែងទើសំរេចបាន ។ ឧទាហរណ៍ ក្នុងនោះមានគោលបំណងផ្នែកតូចៗផ្សេងៗទៀត ។ គំរោង និងសកម្មភាពផ្សេងៗទៀតនឹងចូលរួមចំណែកដើម្បីសំរេចបាននូវគោលបំណងរួមនេះ ។

បញ្ហាចំបងៗ ក្នុងការបង្កើតគំរោង គឺជាគោលបំណងរួម ដែលវាជាសេចក្តីប្រាថ្នាដ៏លើសលប់មួយ រឺក៏និយាយបានថា វាមានការកំណត់បញ្ជាក់ពុំសូវច្បាស់លាស់ ឧទាហរណ៍ :

- o កាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ

- O បង្កើនស្ថានភាពជុំវិញអោយមានលក្ខណៈល្អប្រសើរ
- O បង្កើនកំរិតបទដ្ឋានរស់នៅអោយមានកំរិតខ្ពស់
- O បង្កើនរយៈពេលរស់រានមានជីវិតជាមធ្យម ។

- **គោលបំណង នៃគំរោង (Immediate Objective )**

គោលបំណងនេះ ទទួលបានតាមរយៈការអនុវត្តន៍គំរោង និងក៏ដូចជាធ្វើអោយគំរោងមានអាយុវែងផងដែរ ។ ផលប្រយោជន៍ ដែលមាននិរន្តរភាពសំរាប់ក្រុមគោលដៅនោះ គឺជានិច្ចកាលគឺជាគោលបំណង។ នៅពេលដែលគោលបំណងគំរោង ត្រូវបានកំណត់នោះ ត្រូវច្បាស់លាស់ថា :

- O ត្រូវមានគោលបំណងគំរោងតែមួយ
- O ក្រុមគោលដៅត្រូវបានកំណត់ច្បាស់
- O ត្រូវជាសេចក្តីរំពឹងទុក ក្នុងការចូលរួមបំពេញអោយគោលបំណងរួម
- O មានលក្ខណៈជាក់លាក់ មានន័យថានៅពេលដែលលទ្ធផល (Output) បានសំរេចនោះ គោលបំណងគំរោង ត្រូវបានបំពេញដែរ ។
- O ត្រូវបានបង្កើតឡើងជាទំរង់មួយ ដែលយើងប្រាថ្នាចង់បាន ពុំមែនជាដំណើរការឡើយ ។

☛ **តើត្រូវកំណត់គោលបំណងរបស់គំរោងយ៉ាងដូចម្តេច?**

នៅពេលដែលយើងកំណត់អត្តសញ្ញាណរបស់គំរោងមួយ យើងមានគំនិតខ្លះៗពីអ្វីដែលជាលទ្ធផលដែលគំរោងនឹងផ្តល់អោយ ។ លទ្ធផលដែលគេរំពឹងចង់បានរបស់គំរោងមួយ រឺអ្វីដែលយើងចង់ទទួលបានពីការអនុវត្តន៍គំរោងមួយ គេហៅថា **វត្ថុបំណង រឺគោលបំណង**។ នៅជំហានដំបូងបង្អស់ លទ្ធផលដែលគេរំពឹងចង់បាននៅក្នុងគំរោង រឺគោលបំណង អាចទូលំទូលាយ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីដំណើរការទៅតាមគំនិតនៃគំរោង គេត្រូវកំណត់ និងរៀបចំគោលបំណងអោយបានច្បាស់លាស់ ។

ដោយការកំណត់ រឺរៀបចំគោលបំណង នឹងធ្វើអោយយើងមានគំនិតច្បាស់លាស់ជាមុនពីអ្វីដែលនឹងត្រូវធ្វើ រឺសំរេចបាននៅក្នុងគំរោង។ បើយើងមិនមានគំនិតពិតប្រាកដមួយពីអ្វីដែលយើងចង់បានដោយសារការប្រើធនធានដែលមានសំរាប់គំរោងនោះទេ នោះមានន័យថាយើងខ្ជះខ្ជាយធនធានដែលយើងប្រើនោះ ។ ដូចនេះសំរាប់ការប្រើប្រាស់ដ៏មានប្រសិទ្ធិភាពនូវធនធានដែលមាន វាទាមទារអោយមានការកំណត់នូវគោលបំណងជាក់លាក់របស់គំរោង ហើយការកំណត់នេះ ក៏ជួយអោយការរៀបចំការអនុវត្តន៍ និងការវាយតំលៃគំរោងប្រព្រឹត្តិទៅបានល្អដែរ ។

ក្នុងករណីខ្លះនៅពេលគោលបំណងរបស់គំរោងបានកំណត់ឡើង ជាដំបូងយើងគួរផ្តល់នូវគោលបំណងទូលំទូលាយ រឺគោលបំណងទូទៅសិន Overalll Objective ។ គោលបំណងទូលំទូលាយ រឺគោលបំណងទូទៅ បញ្ជាក់នូវ

ស្ថានភាពទូទៅ រឺស្ថានភាពជារួម ។ បន្ទាប់មកដើម្បីបង្កើតនូវគោលបំណងនេះ យើងត្រូវលំអិតនូវគោលបំណងជាក់-លាក់មួយចំនួន (Specific Objective) ។ **គោលបំណងជាក់លាក់** បង្ហាញនូវចំណុចលំអិតលើគោលបំណងទូទៅ ។

ពេលវេលា/ការកំណត់ដែលទាក់ទងទៅនឹងគោលបំណង គឺជាទិដ្ឋភាពសំខាន់មួយទៀត ដែលគេត្រូវគិតគូរ ។ ដោយយោងទៅតាមពេលវេលា/កាលកំណត់ យើងអាចប្រើវាក្យស័ព្ទមួយចំនួន ដូចជាគោលបំណងរយៈពេលខ្លី គោលបំណងរយៈពេលមធ្យម គោលបំណងរយៈពេលវែង។ ឧទាហរណ៍ក្នុងគំរោងអភិវឌ្ឍន៍សុខភាព ការសាងសង់មន្ទីពេទ្យ គឺជាសមិទ្ធផលភ្លាម១ ហើយអាចចាត់ទុកថាជាគោលបំណងរយៈពេលខ្លី។ ជាការពិតណាស់ មន្ទីរពេទ្យនឹងជួយធ្វើអោយកាន់តែប្រសើរឡើងនូវលក្ខ័ណ្ឌសុខភាពរបស់ប្រជាពលរដ្ឋ ហើយវានឹងកើតមានក្នុងរយៈពេលវែង ហើយក្នុងន័យនេះ ការកែលំអសុខភាពអាចចាត់ទុកជាគោលបំណងរយៈពេលមធ្យម រឺរយៈពេលវែង។

នៅពេលយើងសរសេរចេញនូវគោលបំណងរបស់គំរោង ចូរធ្វើអោយវាមានលក្ខណៈច្បាស់លាស់តាមដែលអាចធ្វើទៅបាន ជៀសវាងនូវការសរសេរក្នុងលក្ខណៈទូលំទូលាយ និងប្រកបដោយមហិច្ឆតា ពីព្រោះភ្នាក់ងារផ្តល់ជំនួយមិនអាចយល់នូវគោលបំណងទាំងនេះ ហើយបន្ទាប់មកគេនឹងបដិសេធន៍នូវសំណើរនេះ ។ លើសពីនេះទៅទៀត គោលបំណងរបស់គំរោងត្រូវតែមានលក្ខណៈពិតជាក់ស្តែង (Realistic) ។

- **លទ្ធផល (Output)**

គឺសំដៅលើលទ្ធផល នៃសកម្មភាពដែលបានអនុវត្តលើផ្នែកផ្សេង១នៃគំរោង ហើយដែលធ្វើអោយអាចសំរេចបាននូវគោលបំណងរបស់គំរោង។ វាគឺជាការចាប់ផ្តើធ្វើអោយមានផលប្រយោជន៍ជានិរន្តរភាពសំរាប់ក្រុមគោលដៅ ។ នៅពេលដែលលទ្ធផល ត្រូវបានកំណត់ឡើង នោះយើងត្រូវអោយច្បាស់ថា :

- O សារៈសំខាន់ នៃលទ្ធផលទាំងឡាយ ត្រូវចាំបាច់ សំរាប់ការសំរេចគោលបំណងគំរោង
- O មានតែលទ្ធផល ដែលអាចធានាបាន ដោយគំរោងប៉ុណ្ណោះទេ ដែលត្រូវបានដាក់បញ្ចូល
- O លទ្ធផលនីមួយ១ អាចជាមធ្យោបាយសំរាប់ធ្វើអោយបានសំរេចដល់គោលបំណងរបស់គំរោង
- O លទ្ធផលទាំងអស់ គឺត្រូវនៅជាមួយធនធាន ដែលអាចរកបាន
- O លទ្ធផលត្រូវមានលក្ខណៈត្រឹមត្រូវជាក់លាក់ ។

- **សកម្មភាព និងពេលវេលា**

គឺជាអំពើដែលត្រូវធ្វើ ដើម្បីបំលែងធនធានរបស់គំរោង ទៅជាលទ្ធផល នៃគំរោងតាមផែនការច្បាស់លាស់ដោយការកំណត់ពេលវេលាច្បាស់លាស់ ។ នៅពេលសកម្មភាពត្រូវបានពិពណ៌នា នោះយើងត្រូវអោយច្បាស់ថា :

- O សកម្មភាពសំខាន់១ទាំងអស់ដែលចាំបាច់សំរាប់បង្កើតលទ្ធផល ត្រូវបានដាក់បញ្ចូល

- o សកម្មភាពទាំងអស់ ត្រូវចូលរួមដោយផ្ទាល់ទៅនឹងកំរិតនៃលទ្ធផល
- o សកម្មភាព ត្រូវលើកឡើង ក្នុងន័យជាអំពើ ដែលត្រូវធ្វើ មិនគួរលើកជាលទ្ធផលសំរេច
- o ពេលវេលាសំរាប់សកម្មភាពនីមួយៗ ត្រូវតែមានលក្ខណៈប្រាកដប្រជា
- o សកម្មភាពត្រូវតែសមស្របជាមួយនឹងស្ថានភាព ។

- **សន្ទស្សន៍ (Indicator)**

គឺគេប្រើប្រាស់សំរាប់ផ្ទៀងផ្ទាត់លើគោលបំណងរួម គោលបំណងគំរោង លទ្ធផល និងសកម្មភាព ។ សន្ទស្សន៍ត្រូវតែបញ្ជាក់អោយបានច្បាស់អំពី :

- o ក្រុមគោលដៅ
- o បរិមាណ
- o ពេលវេលា
- o ទីកន្លែង

សន្ទស្សន៍ ផ្តល់អោយនូវមូលដ្ឋានគ្រឹះ សំរាប់ធ្វើការត្រួតពិនិត្យ និងវាយតំលៃ ។ ជាធម្មតាសន្ទស្សន៍ទាមទារលំអិត ដែលជាតំរូវការនៃការអនុវត្តន៍ ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ ។

សន្ទស្សន៍ ដែលទាក់ទងនឹងគោលបំណងរួម ហាក់ដូចជាមានលក្ខណៈជាគុណភាពជាង ទៅលើលទ្ធផល និងគោលបំណងនៃគំរោង ដែលមានលក្ខណៈជាបរិមាណច្រើនជាង ។

- **មធ្យោបាយផ្ទៀងផ្ទាត់ (Means of Verification)**

គឺជាឯកសារ របាយការណ៍ និងប្រភពផ្សេងៗទៀត ដែលផ្តល់ជាពតិមាន ដែលអាចវាស់ស្ទង់ពីការជឿនលឿនពិតប្រាកដទៅនឹងលទ្ធផលដែលគ្រោងទុក និងគោលបំណង នៃគំរោងដែលត្រូវបានបកស្រាយទៅជាទំរង់ អាចអនុវត្តបានដោយសន្ទស្សន៍ផ្ទៀងផ្ទាត់ជាមួយគោលបំណង ។

- **កត្តាខាងក្រៅ** (Assumption/External Factor)

កត្តាខាងក្រៅ រឺការសន្មត់ទុកជាមុន គឺជាសន្មត់ទុកជាមុនចំពោះហេតុការណ៏ សកម្មភាព រឺទង្វើ ដែលថានឹងកើតមានឡើង ហើយដែលវាទាក់ទងទៅនឹងចំពោះភាពជោគជ័យ រឺបរាជ័យ នៃគំរោង ប៉ុន្តែស្ថិតនៅខាងក្រៅការគ្រប់គ្រងរបស់គំរោង។ កត្តាខាងក្រៅ គឺបានន័យថា ឆ្លើយតបទៅនឹងសំណួរ តើអ្វីជាកត្តាខាងក្រៅ ដែលមិនមានអនុភាពលើគំរោង ប៉ុន្តែអាចមានឥទ្ធិពលដល់ការអនុវត្តន៍ និងស្ថេរភាពយូរអង្វែងរបស់គំរោង ។

## Intervention Logic:

គឺជាយុទ្ធសាស្ត្រជាមូលដ្ឋានដែលគំរោងអាចនឹងគ្របដណ្តប់រាល់ជំហាន ដើម្បីដាក់បញ្ចូលដោយសមស្រប នៃគំរោង ដើម្បីចូលរួមក្នុងការធ្វើអោយសំរេចនូវគោលបំណងរួម តាមទំនាក់ទំនងខាងក្រោម :

- តាមលទ្ធភាព នៃមធ្យោបាយ នាំអោយសកម្មភាពអាចសំរេចបាន
- តាមរយៈសកម្មភាពនេះ លទ្ធផលត្រូវបានទទួល
- តាមរយៈលទ្ធផលទាំងនេះ នាំអោយទទួលបាននូវគោលបំណងនៃគំរោងកម្មវិធី
- តាមរយៈគោលបំណងកម្មវិធីនេះ នាំអោយមានការរួមចំណែកដើម្បីធ្វើអោយសំរេចគោលបំណងរួម ។

គោលបំណងថ្នាក់ខ្ពស់បំផុត ដែលគំរោងចូលរួមដើម្បីអោយបានសំរេច

គោលបំណងជាក់លាក់ នៃគំរោង

លទ្ធផល នៃសកម្មភាពដែលនាំអោយសំរេចបាននូវគោលបំណង នៃគំរោង




កិច្ចសហប្រតិបត្តិការដែលជាផ្នែកមួយ នៃគំរោង

ធនធានស្មារតី និងសំភារៈ ដែលចាំបាច់ សំរាប់ធ្វើសកម្មភាព

### តើត្រូវកំណត់ឋានានុក្រម នៃគោលបំណងយ៉ាងដូចម្តេច?

កូឡោនលំដាប់ នៃការអន្តរាគមន៍ (Intervention Logic) ត្រូវបានរៀបចំដូចខាងក្រោម :

- បំបែកគោលបំណងទៅតាមកំរិតសមស្របនៅក្នុងឋានានុក្រម នៃគោលបំណងតាមវិធីដើមឈើគោលបំណង (Objective Tree)
- បំបែកលំអិតជាបន្តបន្ទាប់នូវគោលបំណងលើមែកនៃដើមឈើគោលបំណង និងបំលែងវាអោយទៅជាលទ្ធផល រឺសកម្មភាព

☞ **ការកំណត់គោលបំណងរបស់គំរោង :**

ជ្រើសរើសគោលបំណងពីផ្នែកខាងលើ នៃបណ្តុំយុទ្ធសាស្ត្ររបស់ដ្យាក្រាម នៃដើមឈើគោលបំណង ។ ធ្វើការជ្រើសរើសដោយប្រើលក្ខណៈវិនិច្ឆ័យជាក់លាក់ ដើម្បីប្រៀបធៀបគោលបំណងផ្សេងៗទៀតនៅក្នុងដ្យាក្រាម នៃដើមឈើគោលបំណង ។

☞ **ការកំណត់គោលបំណងរួម :**

ជ្រើសរើសពីដើមឈើគោលបំណងនូវគោលបំណងមួយ រឺច្រើនពីផ្នែកខាងលើនៃដ្យាក្រាមដើមឈើ ពោលគឺជាគោលបំណងដែលបង្ហាញពីគោលដៅដែលគំរោងចូលរួមវិភាគទានដើម្បីសំរេច ។

☞ **ការកំណត់លទ្ធផល :**

ជ្រើសរើសចេញពីដ្យាក្រាម នៃដើមឈើគោលបំណង នូវគោលបំណងទាំងឡាយណាដែលស្តែងចេញជាផលដែលនឹងទទួលបានបន្ទាប់ពីការអនុវត្តន៍គំរោង ។

☞ **ការកំណត់សកម្មភាព :**

ជ្រើសរើសចេញពីដ្យាក្រាម នៃដើមឈើគោលបំណង ដែលគោលបំណងនោះស្តែងចេញជាលក្ខណៈសកម្មភាពដែលអាចធ្វើអោយសំរេចនូវលទ្ធផល ។

## ការបញ្ជាក់ពីសារៈសំខាន់ នៃឋានានុក្រម នៃគោលបំណង :

☞ **តើគោលបំណងរួមមានសារៈសំខាន់យ៉ាងដូចម្តេច?**

គោលបំណងរួមបង្កើតជារូបភាពទូទៅមួយ ដែលក្នុងនោះគេត្រូវអនុវត្តនូវគំរោងដែលយើងបង្កើតឡើងនេះ ដើម្បីសំដៅឈានទៅដល់រូបភាពនោះ។ គំរោងផ្សេងៗទៀតក្រៅពីគំរោងដែលយើងបង្កើតឡើងនេះ ក៏អាចចូលរួមចំណែក ដើម្បីសំរេចបាននូវគោលបំណងរួមនេះផងដែរ ។

☞ **តើគោលបំណងគំរោង មានសារៈសំខាន់យ៉ាងដូចម្តេច?**

គោលបំណងរបស់គំរោង គឺជាចំណុចគន្លឹះហើយដែលគេប្រើជាឯកសារយោងសំរាប់ការគ្រប់គ្រង និងការវាស់វែងពីជ័យជំនះ រឺបរាជ័យនៃគំរោង ។ ក្នុងការគ្រប់គ្រងគំរោង គេត្រូវធ្វើយ៉ាងណាដើម្បីអោយប្រាកដថាគោលបំណង នៃគំរោងគឺត្រូវបានសំរេច ។

☞ **ពេលណាគំរោងត្រូវបញ្ចប់?**

គំរោងមួយ នឹងត្រូវបានបញ្ចប់នៅពេលដែលគោលបំណងរបស់គំរោងនោះត្រូវបានសំរេច មានន័យថានៅពេលដែល ផលិតផល (Output) ត្រូវបានបង្កើតឡើង នឹងត្រូវបានប្រើប្រាស់ដើម្បីជាផលចំណេញ នៃក្រុមគោលដៅជាមួយនឹងការជឿជាក់ថាស្ថានភាពនេះនឹងបន្តទៅទៀត ។ គំរោងបានទៅដល់ចំណុចដែលមិនអាចត្រឡប់វិញបាន ។

☞ **តើលទ្ធផល នៃគំរោងត្រូវបានសំរេចដូចម្តេច?**

វាលេចឡើងពីដ្យាក្រាម នៃដើមឈើគោលបំណងផង និងពីការសិក្សាបច្ចេកទេសជាក់លាក់ផង ។

☞ **តើសកម្មភាពត្រូវបានសំរេចយ៉ាងដូចម្តេច?**

- ទាញចេញពីដ្យាក្រាម នៃដើមឈើគោលបំណង
- លេចចេញពីការសិក្សាជាក់លាក់លើគំរោង
- លេចចេញពីការសិក្សាជាមួយក្រុមផ្សេងៗដែលចូលរួម ។

# ផែនការសកម្មភាព
# Implementation Plan

ការធ្វើផែនការសកម្មភាពសំរាប់ការបំពេញការងារ ជាការលំអិតបន្ថែមលើគំរោងការនៃគំរោង។ ជំហានដំបូង នៃការបង្កើតផែនការលំអិតមួយ គឺជាការកំណត់បញ្ជាក់សកម្មភាពដែលអ្នកត្រូវអនុវត្ត ដើម្បីសំរេចបាននូវគោលបំណង។ នៅពេលជាមួយគ្នានេះ យើងត្រូវតែកំណត់អ្វីដែលជាកត្តាដែលជំរុញអោយមានការរីកចំរើនសំរាប់សកម្មភាពនីមួយៗ និងថាតើយើងវាស់វែងដោយរបៀបណា ។

## ក. តើសកម្មភាពជាអ្វី?

សកម្មភាពជាជំហានតូចៗ ដែលត្រូវបំពេញដើម្បីអោយអាចសំរេចនូវគោលបំណងរបស់យើង ។

## ខ. លក្ខណៈរបស់សកម្មភាព

ជាទូទៅសកម្មភាពមានលក្ខណៈដូចខាងក្រោម :

- បន្ថែមព័ត៌មានលំអិតអោយគោលបំណង រឺលទ្ធផលរំពឹងទុក
- ជាទូទៅវាមានពេលវេលាចាប់ផ្តើម និងពេលវេលាបញ្ចប់ច្បាស់លាស់
- ទាមទារអោយមានមធ្យោបាយ រឺធនធានដើម្បីសំរេច ។ ឧទាហរណ៍ដូចជា ហិរញ្ញវត្ថុ បុគ្គលិក សំភារៈ ឧបករណ៍ ជាដើម ។ល។
- មានលទ្ធផលច្បាស់លាស់ ហើយមានសន្ទស្សន៍ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់យើង ។

## គ. ជំហានក្នុងការបង្កើតសកម្មភាព

១. បំបែកគោលបំណង រឺលទ្ធផលរំពឹងទុកអោយទៅជាជំហានតូចៗ

២. កំណត់សន្ទស្សន៍សំរាប់វាស់វែងការរីកចំរើនក្នុងការអនុវត្តន៍សកម្មភាព

៣. កំណត់ការវាស់វែង និងផ្ទៀងផ្ទាត់សន្ទស្សន៍ ( ការបង្កើតមធ្យោបាយផ្ទៀងផ្ទាត់) ។

## ឃ. ផែនការសកម្មភាព

បន្ទាប់ពីបានបំពេញសកម្មភាពដែលត្រូវធ្វើ វាជាពេលដែលត្រូវទៅកាន់ជំហានដែលនៅសល់ក្នុងដំណើរការនៃការធ្វើផែនការសកម្មភាព ។ ដើម្បីធ្វើដូចនេះ ចូរបំពេញនូវជំហានដូចខាងក្រោម :

☛ **ជំហានទី ១ : កំណត់ធនធានដែលត្រូវការ**

សំរាប់សកម្មភាពនីមួយៗ យើងប្រហែលជាត្រូវការធនធានដូចខាងក្រោមមួយ រឺច្រើន ដើម្បីបំពេញវា :

- ឧបករណ៍
- សំភារៈ និងការផ្គត់ផ្គង់
- បុគ្គលិក
- ថវិកា

ចូរធ្វើបញ្ជីមួយ នៃធនធានដែលអ្នកត្រូវការសំរាប់សកម្មភាពនីមួយៗ លើកលែងតែថវិកាដែលនឹងត្រូវបានគេចាត់ទុក ដោយឡែកពីគេនៅពេលធ្វើថវិកាគំរោង ។

### ☛ ជំហានទី ២ : កំណត់រយៈពេល នៃសកម្មភាព

កំណត់ថា តើវាត្រូវចំណាយពេលប៉ុន្មាន ដើម្បីបំពេញសកម្មភាពនីមួយៗ។ ប៉ុន្តែកុំទាន់កំណត់ថា យើងនឹងចាប់ផ្តើមបំពេញ រឺបញ្ចប់វានៅពេលណា ។ សូមចងចាំថា :

- សកម្មភាពខ្លះត្រូវការរយៈពេលយូរដើម្បីបង្ហាញលទ្ធផល
- សំរាប់សកម្មភាពដែលកំពុងបន្ត រឺកើតឡើងដដែលៗ ត្រូវបញ្ជាក់ថាតើគេត្រូវការពេលប៉ុន្មាន ដើម្បីធ្វើសកម្មភាពទាំងនេះ ។

### ☛ ជំហានទី៣ : លំដាប់លំដោយនៃសកម្មភាព

យើងត្រូវកំណត់ថា ក្នុងលំដាប់ណាយើងអនុវត្តជំហានតូចៗទាំងនេះ មានន័យថាសកម្មភាព រឺជំហានមួយណាត្រូវធ្វើមុនគេ ហើយបន្ទាប់មកសកម្មភាពណា ។ វិធីមួយទៀត ត្រូវចែកសកម្មភាពទាំងនេះទៅជាបីក្រុម គឺការរៀបចំ ការអនុវត្តន៍ និងការតាមដាន ។

### ☛ ជំហានទី៤ : ការកំណត់អ្នកទទួលខុសត្រូវលើសកម្មភាព

យើងត្រូវសំរេចថា តើអ្នកណាជាអ្នកទទួលខុសត្រូវទាំងមូលក្នុងការបំពេញសកម្មភាពនីមួយៗ វាពុំមានន័យថាមានតែអ្នកនោះទេ ដែលអាចធ្វើសកម្មភាពនោះបាន ប៉ុន្តែវាមានន័យថាអ្នកនោះជាអ្នកទទួលខុសត្រូវក្នុងការបំពេញសកម្មភាពដែលកំណត់នោះ ។

- ជាញឹកញាប់ កាតព្វកិច្ចពិសេសៗត្រូវបានកំណត់ក្នុងការពិពណ៌នាការងារ (Job Description) របស់មនុស្សម្នាក់
- ពិនិត្យមើលបន្ទុកការងាររបស់អ្នកណាម្នាក់ ហើយមិនត្រូវបង្កើនបន្ទុកនេះដល់ចំនុចមួយដែលមិនអាចសំរេចបានឡើយ
- ត្រូវប្រគល់កាតព្វកិច្ចដល់អ្នកដែលមានវត្តមានតែប៉ុណ្ណោះ ។

### ☛ ជំហានទី ៥ : កំណត់ពេលចាប់ផ្តើម និងពេលបញ្ចប់

ជំហានចុងក្រោយ គឺការធ្វើបន្ទាត់ពេលវេលាមួយ ។ បន្ទាត់ពេលវេលាបង្ហាញនៅពេលណាសកម្មភាពមួយនឹងចាប់ផ្តើម ហើយវានឹងបញ្ចប់នៅពេលណា ។

- កុំធ្វើបន្ទាត់ពេលវេលាវែងពេក គឺត្រឹមតែជុំវិញ ៦ ខែគឺជាការល្អបំផុត
- កុំធ្វើបន្ទាត់ពេលវេលារបស់អ្នកអោយពេញពេក ពីព្រោះថារឿងរ៉ាវដែលមិនបានគិតទុកមុន តែងតែកើតឡើង ហើយអ្នកត្រូវមានពេលវេលាបំរុងមួយសំរាប់ប្រឈមមុខនឹងព្រឹត្តិការណ៍ទាំងនោះ
- ត្រូវយកការប្តេជ្ញាចិត្តរបស់បុគ្គលិកមកគិត។ បុគ្គលិកខ្លះអាចធ្វើការក្នុងគំរោងដទៃទៀតផងដែរ រឺមានការទទួលខុសត្រូវផ្សេងទៀតបន្ថែមទៅនឹងគំរោងដែលអ្នកកំពុងធ្វើផែនការ ។

**តារាងគំរូផែនការសកម្មភាព**

| **សកម្មភាព** | **ជំហាន/លំអិត** | **ធនធានត្រូវការ** | **អ្នកទទួលខុសត្រូវ** | **ឆ្នាំ២០០៦** | | | |
|---|---|---|---|---|---|---|---|
| | | | | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# ការរៀបចំផែនការថវិកា
# Project Budgeting

ក្រោយពីបានគិតពីសកម្មភាព និងធនធានបានចប់សព្វគ្រប់ហើយ យើងអាចចាប់ផ្តើររៀបចំគំរោងថវិកាបាន ។ ពតិមានសំខាន់សំរាប់រៀបចំថវិការួមមាន : បញ្ជីផែនការសកម្មភាពលំអិត និងបញ្ជីធនធានដែលត្រូវការ ។ មានគំរោងថវិកាល្អ នាំអោយយើងអាចជៀសវាងនូវការអូសបន្លាយពេល នៃការអនុវត្តន៍គំរោងកម្មវិធី ការខ្វះថវិកា និងធនធាន រឺការខកខានមិនបានអនុវត្តសកម្មភាព ។

## ក. តើផែនការថវិកាជាអ្វី ?

ផែនការថវិកាគឺជាការប៉ាន់ប្រមាណ ជាផែនការចាយវាយដែលអាចកំណត់អោយដឹងថាតើត្រូវការថវិកាប៉ុន្មាន ហើយថវិកានេះ ត្រូវចាយវាយដោយរបៀបណា នៅក្នុងអំឡុងពេលអនុវត្តគំរោង ។

## ខ. អត្ថប្រយោជន៍ នៃការរៀបចំថវិកាគំរោង

- ជាឧបករណ៏សំរាប់រៀបចំផែនការ
  - o ដើម្បីកំណត់ការប្រើប្រាស់ធនធាន
  - o ដើម្បីប៉ាន់ប្រមាណចរន្តសាច់ប្រាក់
  - o ដើម្បីកំណត់អាទិភាព
  - o ដើម្បីគាំទ្រគំរោងការ
- **ជាឧបករណ៏សំរាប់គ្រប់គ្រង**
  - o ដើម្បីអោយអ្នកគ្រប់គ្រងទាំងឡាយអោយបានដឹងពីការទទួលខុសត្រូវរបស់គេចំពោះផ្នែកហិរញ្ញវត្ថុ
  - o ដើម្បីតាមដាន និងត្រួតពិនិត្យការចាយវាយផ្សេងៗ
  - o ដើម្បីប្រៀបធៀប ចំណូល និងចំណាយជាក់ស្តែងដោយប្រៀបធៀបទៅនឹងគំរោងថវិកាដើមក្នុងគោលបំណងតាមដានមើលលទ្ធផលដែលបានសំរេច ។

## គ. ចំនុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ក្នុងពេលរៀបចំថវិកា

- **គំរោងថវិកាត្រូវតែមានលក្ខណៈច្បាស់លាស់មានទស្សនៈបីយ៉ាង :**
  - o ប្រសិនបើមានការប្រែប្រួលនូវតំលៃ រឺផែនការ វាធ្វើអោយមានការងាយស្រួលក្នុងការពន្យល់ពីហេតុផលថាតើហេតុអ្វីបានជាចំណាយមិនដូចទៅនឹងផែនការ.

- o មានលក្ខណៈងាយស្រួលសំរាប់អ្នកដទៃ ធ្វើការផ្ទៀងផ្ទាត់លើថវិកាក្នុងករណីដែលមានភាពមិនច្បាស់លាស់
- o មានលក្ខណៈងាយស្រួលក្នុងការត្រួតពិនិត្យការចាយវាយ ។ ព្រោះថាយើងមិនអាចចាំបានសព្វគ្រប់នូវអ្វីដែលយើងបានចំណាយកាលពីពេលកន្លងមកឡើយ ។

- **គំរោងថវិកាត្រូវតែមានលក្ខណៈលំអិត**
  - o ត្រូវគិតបញ្ចូលនូវតំលៃមុខចំណាយទាំងអស់ដែលយើងបានគ្រោងទុកក្នុងផែនការសកម្មភាព ។ វាពុំមែនជាមធ្យោបាយល្អទេ ដែលក្រោយពេលបានទទួលការឧបត្ថម្ភថវិកា យើងទើបតែដឹងថាមានការខ្វះខាត ហើយយើងនឹងនិយាយទៅកាន់អ្នកឧបត្ថម្ភថវិកាថា សូមទោស ខ្ញុំភ្លេចបញ្ចូលថ្លៃចំណាយលើ..........ទៅក្នុងគំរោងថវិកា ។
  - o ត្រូវគិតអោយបានលំអិត និងប្រើឯកតាអោយបានច្បាស់លាស់ ។
- **គំរោងថវិកាត្រូវមានលក្ខណៈត្រឹមត្រូវ**
  - o ដោយសារតែជំនួយមានកំណត់ នោះទាមទារអោយមានការគ្រោងតំលៃចំណាយបានត្រឹមត្រូវ ជៀសវាងការគ្រោងថវិកាច្រើន ហើយប្រើប្រាស់មិនអស់ រឺប្រើប្រាស់មិនសមស្រប
  - o ប្រការដូចខាងលើ អាចនាំអោយបាត់បង់ការជឿទុកចិត្តពីម្ចាស់ជំនួយ ព្រោះការគ្រោងរបស់យើងពុំសមស្រប
  - o ប្រសិនបើយើងចង់មានទំនាក់ទំនងវែងឆ្ងាយជាមួយអ្នកផ្តល់ជំនួយនោះយើងត្រូវ ប៉ាន់ប្រមាណទឹកប្រាក់អោយបានសមស្រប, ប៉ាន់ប្រមាណតំលៃអោយត្រឹមត្រូវ និងគណនាអោយសុក្រិត្យ ។
- **ឆ្នាំសារពើពន្ធ :**

ជារយៈពេលមួយឆ្នាំដែលប្រើប្រាស់ក្នុងផ្នែកគណនេយ្យ និងការរៀបចំថវិកា ។ ឆ្នាំសារពើពន្ធដែលគេនិយមប្រើមាន :

- o ០១ មករា ដល់ ៣១ ធ្នូ
- o ០១ កក្កដា ដល់ ៣០ មិថុនា
- o ០១ តុលា ដល់ ៣០ កញ្ញា

ការកំណត់ឆ្នាំសារពើពន្ធនេះ អាចខុសពីខាងលើអាស្រ័យតាមលក្ខណៈជាក់ស្តែង នៃគំរោងនីមួយៗ ។

- **ខ្ទង់ចំណាយ**

ដើម្បីអោយគំរោងថវិកាច្បាស់លាស់ យើងត្រូវបែងចែកថវិកាជាផ្នែក ។ ផ្នែកនីមួយៗហៅថាខ្ទង់ចំណាយ ។ យើងគួរលៃលកយ៉ាងណាកុំអោយមានខ្ទង់ចំណាយច្រើនពេក រឺតិចពេក ។ ភាគច្រើនគេនិយមប្រើខ្ទង់ចំណាយពី ៧-

១០ខ្ទង់ ។

- **ចំណាយឥតព្រាងទុក**

ជាទឹកប្រាក់ត្រៀមសំរាប់ចំណាយទៅលើអ្វីដែលមិនបានព្រាងទុក ។ ប៉ុន្តែយើងគួរមានការប្រុងប្រយ័ត្ន បើសិនជាខ្ទង់ចំណាយឥតព្រាងទុកនេះធំពេក នោះវាឆ្លុះបញ្ចាំងថាសមត្ថភាពធ្វើផែនការរបស់យើងនៅទាប ។ ចំណាយឥតព្រាងទុក គួរគ្រោងពី ១ ទៅ ៥ ភាគរយ នៃថវិកាសរុបតាមខ្ទង់ ។

- **វិភាគទានមិនមែនសាច់ប្រាក់**

ការឧបត្ថម្ភជាសំភារៈ រឺសេវាផ្សេងៗ ក៏ត្រូវដាក់បង្ហាញនៅក្នុងគំរោងថវិកា ដើម្បីបង្ហាញដល់អ្នកឧបត្ថម្ភថវិកាពីមធ្យោបាយដែលយើងដោះស្រាយតំរូវការដោយពុំបាច់តែសាច់ប្រាក់ឡើយ ។ វិភាគទានមិនមែនសាច់ប្រាក់ត្រូវដាក់បង្ហាញនៅក្នុងជួរឈរមួយដោយឡែក ពីជួរឈរ នៃតំរូវការថវិកា ។

- **ចំណាយរដ្ឋបាល**

ជាចំណាយដែលយើងប្រើប្រាស់សំរាប់ទ្រទ្រង់ការងារគំរោងកម្មវិធី ។ ចំណាយនេះរួមមាន បុគ្គលិក សំភារៈការិយាល័យ អគ្គសនី មធ្យោបាយដឹកជញ្ជូន ។ល។

## ឃ. ប្រភេទ នៃដំណើរការរៀបចំថវិកា

- **ពីលើទៅក្រោម :**

អ្នកគ្រប់គ្រងថ្នាក់ខ្ពស់រៀបចំគំរោងថវិកា ដែលមានបែងចែកទៅតាមផ្នែកនីមួយៗ

- **ពីក្រោមទៅលើ :**

អ្នកគ្រប់គ្រងគំរោងរៀបចំគំរោងរៀងៗខ្លួន ហើយយកមកពិភាក្សាជាមួយអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ដើម្បីដាក់បញ្ចូលទៅក្នុងថវិការួម ។

- **គំរោងថវិកាដោយមានការចូលរួម :**

អ្នកគ្រប់គ្រងគំរោងកម្មវិធីត្រូវទទួលការណែនាំពីអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ហើយរៀបចំថវិកាតាមគំរោងរៀងៗខ្លួន បន្ទាប់មកមានការកែសំរួលពីអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ដើម្បីរៀបចំជាថវិការួម ។

# ការត្រួតពិនិត្យ និងការវាយតំលៃគំរោង
# Project Monitoring and Evaluation

## ១. ការត្រួតពិនិត្យជាអ្វី?

ការត្រួតពិនិត្យ គឺជាការតាមដាន ពិនិត្យជាបន្តបន្ទាប់ លើសកម្មភាព និងដំណើរការប្រតិបត្តិគំរោង ដើម្បីស្វែងយល់ថាតើការប្រតិបត្តិជាក់ស្តែង ដើរតាមផែនការដែលបានគ្រោងទុកដែរឺទេ ទន្ទឹមនឹងនេះគឺធ្វើការផ្ទៀងផ្ទាត់ការរីកចំរើននៃគំរោង ហើយធ្វើការកែតំរូវការប្រតិបត្តិក្នុងករណីចាំបាច់។ ការត្រួតពិនិត្យចែកចេញជាពីរផ្នែកធំៗ :

- ការត្រួតពិនិត្យលើកម្មវិធី (Program Monitoring)
- ការត្រួតពិនិត្យលើរចនាសម្ព័ន្ធ នៃការគ្រប់គ្រង (Monitor the organizational management)

**ក. ការត្រួតពិនិត្យកម្មវិធី (Program Monitoring)**

- **ការត្រួតពិនិត្យលើការប្រតិបត្តិ :** គឺជាការត្រួតពិនិត្យលើចំនួនអ្នកទទួលផល ស្ថានភាពអ្នកទទួលផល ធនធាននានាសំរាប់កម្មវិធីជំហាននៃការអនុវត្តន៏គំរោង ពេលវេលាដែលត្រូវប្រតិបត្តិសកម្មភាពលទ្ធផល សេវាកម្មនានា ។
- **ការត្រួតពិនិត្យលើប្រសិទ្ធិភាព :** គឺជាការត្រួតពិនិត្យដោយយោងទៅតាមគោលបំណងគំរោងដែលបានកំណត់។ ជាទូទៅការត្រួតពិនិត្យរបៀបនេះ ផ្តល់ឳកាសអោយយើងស្វែងយល់ថា លទ្ធផលនានាដែលផលិតដោយសកម្មភាពនឹងអាចដឹកនាំឆ្ពោះទៅសំរេចគោលបំណងគំរោងដែរឺទេ។ យើងក៏អាចដឹងផងដែរពីសន្ទុះ រឺសក្តានុពល នៃគំរោងក្នុងដំនាក់កាលនីមួយៗ នៃការត្រួតពិនិត្យ ។
- **ការត្រួតពិនិត្យឥទ្ធិពល :** ជាទូទៅគេកំរត្រួតពិនិត្យលើឥទ្ធិពលណាស់ ព្រោះការសិក្សាលើឥទ្ធិពល ច្រើនធ្វើទៅបាន នៅពេលវដ្តនៃគំរោងត្រូវបានបញ្ចប់ភ្លាម រឺធ្វើក្រោយពីគំរោង ត្រូវបានបញ្ចប់មួយរយៈ ។

**ខ. ត្រួតពិនិត្យការគ្រប់គ្រងអង្គការ (Monitor oranizational management)**

ជាទូទៅការត្រួតពិនិត្យរបៀបនេះ ច្រើនធ្វើដោយម្ចាស់ទុន ប៉ុន្តែក្រុមគ្រប់គ្រងរបស់ អង្គការនីមួយៗក៏គួរធ្វើការត្រួតពិនិត្យទៅលើចំនុចទាំងអស់ដូចខាងក្រោមនេះ ព្រោះវាជួយអោយអង្គការនីមួយៗមានលក្ខណៈកាន់តែសុក្រិត

១. រចនាសម្ព័ន្ធអង្គការ
២. ការទំនាក់ទំនងខាងក្នុងអង្គការ
៣. ការគ្រប់គ្រងបុគ្គលិក
៤. ការគ្រប់គ្រងថវិកា
៥. ឯកសាររដ្ឋបាល

៦. ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

៧. ទំនាក់ទំនងខាងក្រៅអង្គការ ។

ដូចជាទំនាក់ទំនងជាមួយម្ចាស់ទុន ដាក់បណ្តាញជាមួយអង្គការ រឺស្ថាប័ននានា ។ ចំពោះការវាយតំលៃលើរចនាសម្ព័ន្ធ នៃការគ្រប់គ្រង គឺគេអាចវាយតំលៃលើចំនុចទាំងអស់ខាងលើ ។ ទន្ទឹមនឹងនេះ គេនឹងសិក្សាលើចំនុចថ្មីមួយទៀតគឺ ( SWOT = ចំនុចខ្លាំង ចំនុចខ្សោយ ឱកាស ការបារម្ភ ) ។

**☛ ហេតុអ្វីចាំបាច់ធ្វើការត្រួតពិនិត្យ? (សារៈសំខាន់ នៃការត្រួតពិនិត្យ) :**

១. ទទួលខុសត្រូវជាមួយអ្នកមានតួនាទីខ្ពស់ជាង (Accountability)

២. ដើម្បីតាមដានពីការប្រតិបត្តិជាក់ស្តែង ដោយប្រៀបធៀបទៅនឹងផែនការដែលបានគ្រោង

៣. ស្វែងយល់ពីការរីកចំរើននានា នៃគំរោងដែលឆ្ពោះទៅសំរេចគោលបំណង

៤. កំណត់រកបញ្ហាដែលអាច រឺកំពុងរាំងស្ទះការប្រតិបត្តិ រឺឧបសគ្គនានាពាក់ព័ន្ធដំណើរការ

៥. រកដំណោះស្រាយអោយទាន់ពេលវេលា (ក្នុងករណីចាំបាច់ អាចកែលំអយុទ្ធសាស្ត្រដំណើរការប្រតិបត្តិនានាដើម្បីទទួលបានសមិទ្ធិផលសមស្របនាពេលអនាគត)

៦. តំរង់ទិសដៅការងារឆ្ពោះទៅសំរេចគោលបំណង

៧. ធនធានត្រូវបានគេយកទៅប្រើប្រាស់បានសមស្រប

៨. ដើម្បីផ្តល់នូវរបាយការណ៍ នៃព្រឹត្តិការណ៍នានា

៩. ដើម្បីផ្តល់នូវពត៌មាន សំរាប់ការវាយតំលៃក្នុងពេលអនាគត ។

**☛ បញ្ហាដែលគេធ្លាប់ជួបប្រទះក្នុងការត្រួតពិនិត្យ នៃការប្រតិបត្តិគំរោង មាន :**

១. ពុំមានការប្រតិបត្តិតែម្តង រឺប្រតិបត្តិពុំពេញលេញលក្ខណៈ តាមអ្វីដែលគេបានគ្រោង ឧទាហរណ៍ប្រើធនធានតិចជាង ពុំបានប្រតិបត្តិតាមជំហាននានា នៃកម្មវិធី ។ល។

២. ការប្រតិបត្តិខុសទិសដៅ ឧទាហរណ៍ការអប់រំដែលមានលក្ខណៈបច្ចេកទេសខ្ពស់, ការអប់រំពីអាហារបំប៉ននានាដែលអ្នកភូមិពុំអាចរកបានក្នុងសហគមន៍គាត់, ជ្រើសរើសអ្នកទទួលផលដែលពុំមែនជាអ្នកក្រីក្រ ។ល។

៣. ការប្រតិបត្តិពុំមានលក្ខណៈជាស្តង់ដា ឧទាហរណ៍ការផ្តល់សេវាកម្មប្លែកៗពីគ្នាលើគំរោងកម្មវិធីដូចគ្នា គ្រាន់តែប្រតិបត្តិនៅភូមិខុសគ្នា

**☛ តើអ្នកណាខ្លះ គួរធ្វើគំរោងត្រួតពិនិត្យលើគំរោងកម្មវិធី?**

អ្នកមានតួនាទីត្រួតពិនិត្យកម្មវិធី អាចរាប់បញ្ចូលចាប់ពីគណៈកម្មការនានាដែលមានក្នុងរចនាសម្ព័ន្ធថ្នាក់ភូមិរហូតដល់បុគ្គលិកប្រតិបត្តិកម្មវិធី និងរួមគ្រប់គ្រងអង្គការ ។ ប៉ុន្តែទំហំការងារត្រួតពិនិត្យរបស់អ្នកពាក់ព័ន្ធទាំងអស់មិនដូចគ្នាទេ វាអាស្រ័យលើការបែងចែកការទទួលខុសត្រូវ នៃបុគ្គលិកម្នាក់ៗ ។

**☛ តើត្រូវត្រួតពិនិត្យញឹកញាប់ប៉ុណ្ណា?**

ភាពញឹកញាប់ នៃការត្រួតពិនិត្យគឺអាស្រ័យនឹងកត្តាមួយចំនួនដូចខាងក្រោម :

- ទំហំ និងភាពស្មុគស្មាញ នៃគំរោង
- ស្ថានភាពគំរោង ( គំរោងចាស់ រឺថ្មី)
- សមត្ថភាពបុគ្គលិកដែលប្រតិបត្តិគំរោង
- តម្លាភាព នៃអ្នកគ្រប់គ្រង ។ល។

ដូចនេះក្នុងករណីគំរោងថ្មី ស្មុគស្មាញ សមត្ថភាពបុគ្គលិកប្រតិបត្តិនៅមានកំរិត ។ល។ នោះថ្នាក់គ្រប់គ្រងអង្គការ រឺម្ចាស់ទុន ត្រូវធ្វើការចុះត្រួតពិនិត្យអោយបានញឹកញាប់ដើម្បីជួយតំរង់ទិស នៃការប្រតិបត្តិ និងជួយដោះស្រាយបញ្ហានានា ។

**☛ តើការត្រួតពិនិត្យធ្វើសំរាប់អ្នកណា?**

១. ម្ចាស់ទុន ( ដើម្បីទាក់ទាញការគាំទ្របន្ត)

២. អង្គការផ្ទាល់ខ្លួន ដើម្បីតំរង់ទិសកម្មវិធី កែលំអការប្រតិបត្តិ និងដោះស្រាយបញ្ហាអោយទាន់ពេលវេលា

៣. អ្នកទទួលផល ( ទទួលបានផលប្រយោជន៍ត្រឹមត្រូវពីកម្មវិធី) ។

**☛ ជំហាននៃការត្រួតពិនិត្យ : កំណត់កម្មវិធីដែលធ្វើការត្រួតពិនិត្យ**

↓

**កំណត់គោលបំណងជាក់លាក់ ( តើយើងត្រួតពិនិត្យលើចំនុចអ្វី ធ្វើនៅពេលណា)**

↓

**ប្រមូលឯកសារ របាយការណ៍ដែលពាក់ព័ន្ធ និងអានឯកសារ/របាយការណ៍ទាំងនេះដើម្បីទទួលបានពត៌មានពីកម្មវិធី**

↓

**ស្រង់ពត៌មានដែលពុំទាន់ច្បាស់លាស់ ដើម្បីទទួលការស្រាយបំភ្លឺពីអ្នកដែលពាក់ព័ន្ធ**

↓

**កំណត់ទិន្នន័យ រឺសន្ទស្សន៍ផ្សេងៗដែលយើងត្រូវធ្វើការត្រួតពិនិត្យ**

↓

**កំណត់មនុស្ស រឺក្រុមដែលយើងអាចទទួលបានទិន្នន័យខាងលើ**

↓

**ចុះត្រួតពិនិត្យជាក់ស្តែង**

↓

**សរសេររបាយការណ៍ត្រួតពិនិត្យ**

**សូមចងចាំ :** ជាទូទៅការត្រួតពិនិត្យ និងវាយតំលៃមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត និងមានតួនាទីប្រហាក់ប្រហែលគ្នាក្នុងការគ្រប់គ្រងគំរោង ហើយការត្រួតពិនិត្យបានទៀងទាត់ត្រឹមត្រូវ និងច្បាស់លាស់អាចធានាដល់ភាពជោគជ័យនៃគំរោង។ ប៉ុន្តែគេសង្កេតឃើញមានភាពខុសគ្នាជាមូលដ្ឋានរវាងការត្រួតពិនិត្យ និងការវាយតំលៃដូចតារាងខាងក្រោម :

| ការត្រួតពិនិត្យ | ការវាយតំលៃ |
|---|---|
| ១. ផ្ទៀងផ្ទាត់ដំណើរការប្រតិបត្តិជាក់ស្តែងធៀបនឹងផែនការដែលគ្រោង | ១. ត្រួតពិនិត្យថាតើគោលបំណងគំរោងត្រូវសំរេចបានរឺទេ? ធ្វើការប្រៀបធៀបការប្រែប្រួលស្ថានភាពសហគមន៍មុន និងក្រោយពេលប្រតិបត្តិគំរោង |
| ២. មានលក្ខណៈសាមញ្ញជាង | ២. ត្រូវរៀបចំតាមប្រព័ន្ធបែបបទ និងបច្ចេកទេសច្បាស់លាស់ |
| ៣. ធ្វើដោយអ្នកខាងក្នុង | ៣. ធ្វើដោយអ្នកខាងក្រៅ |
| ៤. ធ្វើជាទៀងទាត់ និងធ្វើបន្តបន្ទាប់ក្នុងពេលគំរោងកំពុងដំណើរការប្រតិបត្តិ | ៤. អាចធ្វើតែពាក់កណ្តាលវដ្ត នៃគំរោង រឺពេលគំរោងត្រូវបានបញ្ចប់ |
| ៥. ជួយតំរង់ទិសកម្មវិធី កែលំអការប្រតិបត្តិ ។ល។ ដើម្បីនាំឆ្ពោះទៅសំរេចគោលបំណងគំរោង ។ | ៥. ដើម្បីធ្វើការសំរេចចិត្តថា ត្រូវបញ្ឈប់គំរោង រឺមួយគំរោងគួរបន្តទៀត បើបន្តតើគួរកែលំអអ្វីខ្លះ? |

**ការជ្រើសរើសសន្ទស្សន៍ សំរាប់គោលបំណង និងសកម្មភាពនីមួយៗ**

១- ការប្រមូលទិន្នន័យព័តិមានសំរាប់សន្ទស្សន៍នីមួយៗ

២- ការវិភាគទិន្នន័យ

៣- ការបង្ហាញព័តិមានដែលបានរកឃើញ

៤- ការប្រើប្រាស់ព័តិមាន ដើម្បីធ្វើអោយប្រសើរឡើងនូវការអនុវត្តន៍គំរោង ។

## ២. ការវាយតំលៃ

ការវាយតំលៃ គឺជាដំណើរការដើម្បីកំណត់អំពីផលប៉ះពាល់ លទ្ធផលសំរេចបាន និងប្រសិទ្ធភាព នៃគំរោងឬកម្មវិធី ដើម្បីជាបទពិសោធន៍ ឬជាមេរៀនទៅគំរោងក្រោយៗ។ ម្យ៉ាងទៀត ដឹម្បីកំណត់អំពីគោលដៅដែលសំរេចបាន និងគោលបំណងដែលបានគ្រោងទុកមុនពេលចាប់ផ្តើមគំរោង ឬកម្មវិធី។ ការវាយតំលៃដែលមានប្រសិទ្ធភាពគឺមានការចូលរួមពីភាគីខាងក្រៅគំរោង ឬជាលក្ខណៈឯករាជ្យម្ចាស់ការ ។

**តើអ្នកណាអាចធ្វើការវាយតំលៃ?**

រហូតមកដល់ពេលថ្មីៗនេះ គេគិតថាមានតែអ្នកជំនាញទេដែលអាចអនុវត្តការវាយតំលៃបាន ។ ជាការពិតណាស់ គឺមានការវាយតំលៃយ៉ាងច្រើនដែលធ្វើឡើងបានយ៉ាងល្អ ដោយអ្នកដែលបានបណ្តុះបណ្តាលជាលក្ខណៈពិសេស។ នេះជាទូទៅជាប្រភេទ នៃការវាយតំលៃដែលធ្វើឡើងនៅក្នុងមន្ទីរពិសោធន៍ ស្ថាប័ន សាកលវិទ្យាល័យ រឺមន្ទីរពេទ្យ ។

ចុះការត្រួតពិនិត្យ និងវាយតំលៃកម្មវិធីអភិវឌ្ឍន៍ ដែលយកសហគមន៍ជាមូលដ្ឋានតូច រឺធំ យ៉ាងដូចម្តេចដែរ។ មនុស្សជាច្រើនដែលចូលរួមកម្មវិធីសុខភាព កសិកម្ម អភិវឌ្ឍន៍សហគមន៍ និងអប់រំមនុស្សពេញវ័យ បានប្រើប្រាស់វិធីត្រួតពិនិត្យកម្មវិធីរបស់គេក្នុងរយៈពេលជាយូរណាស់មកហើយ ។ វិធីសាស្រ្តទាំងនោះរមែងតែមានការចូលរួមពីសហគមន៍ ។

ទោះជាយ៉ាងណាក៏ដោយ ប្រជាជននៅក្នុងករិតសហគមន៍ រឺក្រ បានប្រមូលពតិមានផ្សេងៗ ដែលទាក់ទងទៅនឹងការងាររបស់គេ ជាធម្មតាគេមានការធ្វើការវិភាគពតិមានទាំងនោះខ្លះ រឺគ្មានធ្វើការវិភាគសោះ ។ គេរមែងតែមិនដឹងច្បាស់លាស់ពីការប្រមូលពតិមាននោះ តើហេតុអ្វីគេត្រូវប្រមូលពតិមាននោះ ពតិមាននោះយកទៅណា គេក៏មិនសង្ឃឹមថា គេឃើញនូវលទ្ធផលនៃការវិភាគរបស់គេផងដែរ។ ទោះជាគេឃើញរបាយការណ៍វាយតំលៃក៏ដោយ ក៏គេមានការលំបាកយល់ពីពាក្យវាយតំលៃរបស់អ្នកជំនាញ និងការបង្ហាញស្ថិតិយ៉ាងស្មុគ្រស្មាញផងដែរ ។ ចំពោះអ្នកធ្វើការក្នុងសហគមន៍ និងប្រធានរបស់គេ គេមានអារម្មណ៍ថាការវាយតំលៃ និងការធ្វើរបាយការណ៍ គឺសំរាប់អ្នកណាម្នាក់ប៉ុណ្ណោះ គឺមិនមែនសំរាប់គេឡើយ ។

របៀបដែលបុគ្គលិកកម្មវិធី និងបុគ្គលិកសហគមន៍ត្រួតពិនិត្យ និងវាយតំលៃការងាររបស់គេដោយរួមមានការកត់ត្រា ការចូលរួមប្រជុំយ៉ាងទៀងទាត់ ការពិភាក្សាផ្សេងៗ គឺដើម្បីធ្វើការប៉ាន់ស្មានភាពជឿនលឿន នៃសកម្មភាព និងសរសេររបាយការណ៍អោយបានទៀងទាត់ប៉ុណ្ណោះ ( ប្រចាំសប្តាហ៍, ខែ, ត្រីមាស និងប្រចាំឆ្នាំ) ។

**អ្នកវាយតំលៃនៅខាងក្នុង និងមកពីខាងក្រៅ តើអ្នកណាអាចផ្តល់លក្ខណៈច្បាស់លាស់ជាងគេ?**

- **អ្នកវាយតំលៃមកពីខាងក្រៅ (External Evaluator) :** គឺជាអ្នកដែលអាចពិនិត្យមើលកម្មវិធីយ៉ាងបរិសុទ្ធ ពីព្រោះគាត់មិនចូលរួមជាលក្ខណៈបុគ្គល ហើយគាត់ក៏មិនបានទទួល រឺបាត់បង់នូវផលប្រយោជន៍បុគ្គល ពីការវាយតំលៃនោះដែរ។ ឧទាហរណ៍អ្នកវាយតំលៃនោះនឹងមិនទទួលរងឥទ្ធិពលខ្លាំងពីបុគ្គលកម្មវិធី រឺភ្នាក់ងារផ្តល់មូលនិធិឡើយ ហើយក៏គ្មានការចូលចិត្ត រឺភាពស្និតស្នាលជាលក្ខណៈបុគ្គលផងដែរ។ ដូច្នេះអាចនិយាយបានថា គាត់មានភាពលំអៀងតិចតួច និងមានលក្ខណៈសត្យានុម័តច្រើន ។

- **អ្នកវាយតំលៃនៅខាងក្នុង (Internal Evaluator) :** គឺជាមនុស្សដែលនៅខាងក្នុងកម្មវិធី រឺអ្នកដែលយល់ដឹងពីកម្មវិធីយ៉ាងច្បាស់ ។ គេបានដឹងពីដំណើរការរបស់គំរោង គោលបំណងបញ្ហា ភាពខ្លាំង និងភាពខ្សោយ ។

ទោះជាយ៉ាងណាក៏ដោយ ដោយគាត់បានដឹងពីកម្មវិធី គាត់អាចអោយគេសន្និដ្ឋានបានថា មានការលំបាកសរសេររបាយការណ៍វាយតំលៃដែលមិនលំអៀង។ ឧទាហរណ៍គាត់អាចទទួលរងយ៉ាងខ្លាំងដោយអារម្មណ៍របស់គាត់ដូចជា : ភាពចូលចិត្ត មិនចូលចិត្ត លក្ខណៈស្និតស្នាល រឺមហិច្ឆតារបស់គាត់ផងដែរ ។ គេអាចនិយាយថា គាត់មានលក្ខណៈអត្តនោម័តច្រើន។ ភាពអត្តនោម័តមិនមែនជាលក្ខណៈអាក្រក់ឡើយ ប៉ុន្តែនៅក្នុងការវាយតំលៃ វាអាចបំផ្លាញការពិតដ៏ត្រឹមត្រូវ និងការសរសេររបាយការណ៍យ៉ាងស្មោះត្រង់។ ខាងក្រោមនេះ គឺជាគុណសម្បត្តិ និងគុណវិបត្តិ នៃអ្នកវាយតំលៃដោយអ្នកដែលនៅខាងក្នុង និងមកពីខាងក្រៅ :

| **អ្នកវាយតំលៃខាងក្រៅ** | **អ្នកវាយតំលៃខាងក្នុង** |
|---|---|
| អាចមើលឃើញយ៉ាងបរិសុទ្ធ (Fresh look) លើកម្មវិធី | ដឹងកម្មវិធីយ៉ាងច្បាស់បំផុត |
| មិនមានការចូលរួមជាលក្ខណៈបុគ្គល ដូច្នេះអាចទទួលបានលក្ខណៈសត្យានុម័តយ៉ាងងាយ | ពិបាកនឹងទទួលបានលក្ខណៈសត្យានុម័ត |
| មិនមែនជាអ្នកមានអំណាចនៅក្នុងរចនាសម្ព័ន្ធ | ជាអ្នកដែលមានអំណាចនៅក្នុងរចនាសម្ព័ន្ធ |
| គ្មានទទួលផលប្រយោជន៍អ្វីពីកម្មវិធីឡើយ តែទទួលបានកិត្យានុភាពពីការវាយតំលៃ | អាចត្រូវបានជំរុញដោយក្តីសង្ឃឹមផ្ទាល់ខ្លួន |
| ត្រូវបានបណ្តុះបណ្តាលពីវិធីវាយតំលៃ អាចមានបទ-ពិសោធន៍ពីការវាយតំលៃផ្សេងៗ ចាត់ទុកជាអ្នកជំនាញក្នុងកម្មវិធី | អាចមិនត្រូវបានបណ្តុះបណ្តាលពីវិធីវាយតំលៃ មានការយល់ដឹងតិច រឺច្រើនជាងគេនៅក្នុងកម្មវិធី |
| អ្នកខាងក្រៅអាចមិនយល់ពីកម្មវិធី រឺអ្នកដែលចូលរួម | មានលក្ខណៈស្និតស្នាល យល់ពីកម្មវិធី អាចបកស្រាយឥរិយាបទ និងអកប្បកិរិយារបស់បុគ្គល |
| អាចធ្វើអោយមានអារម្មណ៍មិនល្អ ចំពោះបុគ្គលិក និងអ្នកចូលរួម មិនច្បាស់លាស់ពីការងាររបស់គាត់ | ដឹងពីកម្មវិធី ដូច្នេះគ្មានឧបសគ្គ នៃការរំខាន ។ ការផ្តល់អនុសាសន៍ចុងក្រោយអាចមានឧបសគ្គតិចតួច |

### តើការវាយតំលៃសំរាប់អ្នកណា?

ពេលខ្លះការវាយតំលៃ ត្រូវបានធ្វើឡើងដោយមានការស្នើឡើងពីអ្នកផ្តល់ជំនួយ ហើយប្រហែលជាគេត្រូវការពត៌មានបន្ថែម រឺចង់ដឹងថាតើគោលការណ៍ និងសកម្មភាពពីមុនមកវាបានជោគជ័យ រឺអត់ ការប្រើប្រាស់ថវិកាបានត្រឹម

ត្រូវ រឺក៏អត់។ បុគ្គលិកកម្មវិធីតាមសហគមន៍អាចយល់ដឹងពីគោលបំណងចំបង នៃការវាយតំលៃដែលជាការងារអនុវត្តជាធម្មតា។ គេចង់ដឹងអំពីអ្វីដែលកម្មវិធីរបស់គេទទួលបានថាតើការប្រឹងប្រែង របស់គេមានប្រសិទ្ធិភាពដែររឺទេ តើធនធានត្រូវបានប្រើប្រាស់បានល្អ ដើម្បីទទួលបាននូវគោលបំណង នៃកម្មវិធីដែររឺទេ ។

នៅពេលដែលការវាយតំលៃត្រូវបានកើតឡើង មនុស្សផ្សេងៗដែលបានចូលរួម អាចមានគោលបំណងជាលក្ខណៈបុគ្គលផ្សេងៗពីគ្នាក្នុងការចូលរួមនោះ។ បើមានការរំពឹងទុក និងក្តីសង្ឃឹមខុសៗគ្នា ដូច្នេះតើវាមានបញ្ហាដែររឺទេ?

បើសិនជាយើងប្រៀបធៀបភាពជឿនលឿន នៃការវាយតំលៃទៅនឹងរថយន្តមួយដែលកំពុងទៅមុខ វាមានលក្ខណៈយ៉ាងច្បាស់ថា ការភាន់ច្រលំខ្លះនឹងកើតមានឡើង បើសិនជាអ្នកដែលចូលរួមវាយតំលៃនោះមានគំនិតខុសគ្នាថាហេតុអ្វីគេមកទីនេះដើម្បីវាយតំលៃ តើគេសង្ឃឹមថាបានអ្វី និងគេចង់ឆ្ពោះទៅសំរេចអ្វី?

មុននឹងការវាយតំលៃចាប់ផ្តើម វាជាការសំខាន់ណាស់ដែលត្រូវដឹងថា តើគេទាំងនោះមានសេចក្តីសង្ឃឹមពីការវាយតំលៃអ្វីខ្លះ។ ពេលខ្លះមានការពិបាកក្នុងការរកដំណោះស្រាយដែលល្អ ដោយមានសេចក្តីសង្ឃឹម និងតំរូវការផ្សេងៗច្រើន។ ស្ថានភាព និងភាពពិតនៃកម្មវិធីពិសេសមួយ នឹងកំណត់អ្វីដែលអាចធ្វើពីការងារនោះ។ អ្វីដែលជាការសំខាន់នោះគឺតំរូវការ និងសេចក្តីសង្ឃឹមផ្សេងៗ នៃបញ្ហាខាងលើនៅក្នុងកំរិតសហគមន៍ត្រូវបានយកចិត្តទុកដាក់ ។ គោលបំណង វិធីសាស្រ្ត និងលទ្ធផល នៃការវាយតំលៃ គួរតែមានការទំនាក់ទំនងយ៉ាងជិតស្និត ទៅនឹងតំរូវការភាពពិត បញ្ហា និងសេចក្តីសង្ឃឹមរបស់គេ ។

### ពេលណាគួរធ្វើការវាយតំលៃ ?

ក្រៅពីមានការត្រួតពិនិត្យ យ៉ាងទៀងទាត់ដែលបានធ្វើឡើងនៅពេលដែលកម្មវិធីកំពុងតែដំណាក់ការ វាក៏ត្រូវធ្វើការវាយតំលៃនៅអំឡុងពេលណាមួយកំណត់ដែរ ដើម្បីជៀសវាងពតិមានកាន់តែច្រើនទៅៗ និងដើម្បីទទួលបានរូបភាពច្បាស់លាស់មួយ នៃការជឿនលឿន និងឥទ្ធិពលនៃកម្មវិធី។ ទោះជាយ៉ាងណាក៏ដោយ ការវាយតំលៃ គឺអាស្រ័យទៅនឹងកត្តាផ្សេងៗ ដែលទាក់ទងនឹងកម្មវិធីដែលមានដូចខាងក្រោម :

១. តើកម្មវិធីនោះមានគោលបំណងរយៈពេលវែងប៉ុណ្ណា? បើសិនជាគោលបំណង នៃកម្មវិធីនោះមានរយៈពេលវែង មិនត្រូវធ្វើការវាយតំលៃឆាប់រហ័សពេកទេ យ៉ាងហោចណាស់ក៏ត្រឹមមួយឆ្នាំ រឺរយៈពេលវែងជាងនេះ

២. តើគោលបំណងនោះមានរយៈពេលខ្លីប៉ុណ្ណា? ឧទាហរណ៏បើកម្មវិធីចាក់វ៉ាក់សាំង ដែលមានរយៈពេលពីរខែ ក្នុងករណីនេះការវាយតំលៃត្រូវធ្វើឡើងនៅចុងបញ្ចប់ នៃកម្មវិធី ។

- តើប្រភេទ នៃវិធីសាស្រ្តត្រួតពិនិត្យអ្វីត្រូវបានយកមកប្រើ? តើរបាយការណ៏ ពតិមានផ្សេងៗ ត្រូវបានប្រមូលពីកន្លែងឆ្ងាយៗមុននឹងការវាយតំលៃចាប់ផ្តើមរឺទេ? តើមានរបាយការណ៏ ពតិមានផ្សេងៗច្រើនត្រូវមើលដែររឺទេ? តើនឹងត្រូវការពេលវេលាច្រើនសំរាប់ធ្វើការងារនេះដែររឺទេ?

- តើអ្នកវាយតំលៃខាងក្រៅចូលរួមក្នុងការវាយតំលៃដែររឺទេ? បើចូលរួម វានឹងមានឥទ្ធិពលដល់ពេលវេលា។ តើពេលណា គេនឹងមក ហើយគេត្រូវការពេលវេលាប៉ុន្មាន ដើម្បីស្វែងយល់ពីកម្មវិធី? តើគេចំណាយពេលប៉ុន្មានក្នុងការងារនេះ?
- តើអំពីរដូវ និងអាកាសធាតុយ៉ាងដូចម្តេចដែរ? នៅក្នុងរដូវវស្សា តើយើងអាចទៅដល់តំបន់ដាច់ស្រយាលបានដែររឺទេ? នៅក្នុងរដូវប្រាំង ទន្លេអាចរីង ហើយយើងមិនអាចធ្វើដំណើរដោយទូកទៅដល់សហគមន៍បាន ។
- តើអំពីពេលវេលា របស់ប្រជាជនវិញយ៉ាងដូចម្តេចដែរ? នៅរដូវប្រមូលផល តើប្រជាជនមានពេលវេលា និងមានការចាប់អារម្មណ៍មកលើការវាយតំលៃដែររឺទេ? នៅក្នុងរយៈពេលណាមួយ នៃឆ្នាំ ប្រជាជនមានការខ្វះខាតស្បៀង និងថវិកា។ តើអាចជ្រើសរើសពេលវេលា ដែលប្រជាជនមិនសូវរវល់ និងចង់ផ្តល់ពេលវេលាដល់ការវាយតំលៃដែររឺទេ? តើចំពោះពេលវេលារបស់បុគ្គលិកវិញយ៉ាងដូចម្តេចដែរ? គេក៏មានពេលរវល់ដែរ ។ តើពេលណា ជាពេលដែលល្អបំផុតសំរាប់គេ ។

## តើការវាយតំលៃត្រូវការប្រើពេលប៉ុន្មាន? (How long will evaluation take?)

ការវាយតំលៃខ្លះត្រូវប្រើរយៈពេល ២-៣ ថ្ងៃ ខ្លះទៀត ប្រើពេលមួយខែ រហូតដល់ច្រើនខែ ។ រយៈពេលដែលត្រូវការសំរាប់វាយតំលៃ វាអាស្រ័យទៅនឹងកត្តាជាច្រើនដែលមានដូចខាងក្រោម :

- រយៈពេលប្រតិបត្តិការកម្មវិធី : តើមានរបាយការណ៍ត្រូវមើលច្រើន រឺតិច?
- ចំនួនប្រជាជនដែលចូលរួម : តើមានអ្នកចូលរួមវាយតំលៃប៉ុន្មាននាក់?
- តើកម្មវិធីពង្រាយទៅលើតំបន់យ៉ាងធំ រឺយ៉ាងណា? តើពីកម្មវិធីមួយទៅកម្មវិធីមួយ មានចំងាយឆ្ងាយ រឺយ៉ាងណា?
- ចំនួនប្រជាជនដែលលះបង់ពេលវេលា ចំពោះការវាយតំលៃ និងចំនួនពេលវេលា ដែលគេអាចលះបង់ប៉ុន្មាន? បើសិនជាមានតែបុគ្គលិកកម្មវិធីចូលរួម គេនឹងដឹងថាអ្នកណាទំនេរ តើវាត្រូវប្រើរយៈពេលអស់ប៉ុន្មាន បើសិនជាអ្នកវាយតំលៃមកពីខាងក្រៅ គេអាចស្នាក់នៅក្នុងរយៈពេលមួយកំណត់ និងអ្នកវាយតំលៃនោះត្រូវការពារពេលវេលាសំរាប់សិក្សាកម្មវិធី ។

## តើការវាយតំលៃនោះ មានតំលៃប៉ុន្មាន (How much will evaluation cost)

ការវាយតំលៃខ្លះ មានតំលៃរាប់ពាន់ដុល្លាអាមេរិក និងការវាយតំលៃខ្លះទៀតមានតំលៃតិចជាង ។ នៅក្នុងរបាយការណ៍វាយតំលៃខ្លះគេមិនបញ្ជាក់ពីតំលៃទេ ។ តំលៃ នៃការវាយតំលៃអាស្រ័យនឹងកត្តាជាច្រើន ដែលមានដូចខាងក្រោម :

- ចំនួនលុយដែលមានសំរាប់ធ្វើការវាយតំលៃ និងប្រភពរបស់វា។ ឧទាហរណ៍តើកម្មវិធីនោះមានគ្រោងថវិកាសំរាប់វាយតំលៃរឺទេ តើការវាយតំលៃនោះ អ្នកណាជាអ្នកចំណាយ (ភ្នាក់ងារផ្តល់ជំនួយរឺអ្នកដែលពាក់ព័ន្ធផ្សេងៗ)
- គោលបំណង និងទំហំនៃការវាយតំលៃ : តើវាមានទំហំធំរឺតូច មានការចំណាយលើការធ្វើដំណើរច្រើនរឺទេ?
- ធនធានសម្ភារៈដែលមាន : (ក្រដាស ថតចំលង....)
- តើបុគ្គលិកកម្មវិធី និងអ្នកក្នុងសហគមន៍ត្រូវការចំណាយបន្ថែមដែរទេ នៅពេលដែលគេធ្វើការលើសម៉ោង?
- តើត្រូវការអ្នកវាយតំលៃមកពីខាងក្រៅដែររឺទេ? តើគេត្រូវការចំណាយលើអ្វីខ្លះ? ចំនួនប៉ុន្មាន?

## ជំហានក្នុងការវាយតំលៃ

ដើម្បីសំរេចបានជោគជ័យនៅក្នុងការវាយតំលៃ យើងត្រូវអនុវត្តតាមជំហានសំខាន់ៗនៅក្នុងការវាយតំលៃដូចតទៅ :

- ការបង្កើតគោលបំណង នៃការវាយតំលៃ
- ការបង្កើតក្រុមវាយតំលៃ
- ការជ្រើសរើសវិធីសាស្ត្រវាយតំលៃ
- ការបង្កើតផែនការវាយតំលៃ
- ការប្រមូលពត៌មាន
- ការធ្វើរបាយការណ៍លទ្ធផល នៃការវាយតំលៃ

### ក. គោលបំណង នៃការវាយតំលៃ

គោលបំណង នៃការវាយតំលៃទាំងអស់ គឺដើម្បីអោយដឹងពីភាពជឿនលឿន នៃកម្មវិធីមួយ ដែលបានអនុវត្តកន្លងមក ថាតើវាអាចទទួលបាននូវគោលបំណងរបស់វាដែររឺទេ ។ ទោះជាយ៉ាងណាក៏ដោយ មានមូលហេតុជាច្រើនដែលរមែងតែមានការពិបាកដើម្បីវាយតំលៃគោលបំណង នៃកម្មវិធីមួយអោយបានច្បាស់លាស់។ ខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះដែលបង្ហាញពីការលំបាកខាងលើ :

- នៅពេលដែលកម្មវិធីបានចាប់ផ្តើម ការបញ្ជាក់ពីគោលបំណង នៃកម្មវិធីមានលក្ខណៈយ៉ាងទូលំទូលាយដូចជាការកាត់បន្ថយភាពឈឺចាប់, ការធ្វើអោយប្រសើរឡើងនូវការរស់នៅ, ក្នុងករណីនេះវាពិបាកធ្វើការវាយតំលៃលើគោលបំណងទាំងនោះណាស់ ។

- ពេលខ្លះគោលបំណង នៃកម្មវិធីទៅពេលមុន មានការផ្លាស់ប្តូរពីពេលមួយទៅពេលមួយ ដោយឆ្លើយតបទៅនឹងតំរូវការចាំបាច់ និងដើម្បីអោយមានការយល់ដឹងកាន់តែច្បាស់ពីបញ្ហា។ ឧទាហរណ៍ កម្មវិធីដែលគេចាប់ផ្តើមពីការអប់រំផ្នែកអាហាររូបត្ថម្ភ និងមានគោលបំណងដើម្បីធ្វើអោយ ប្រសើរឡើងនូវការផ្តល់អាហាររូបត្ថម្ភ ហើយបន្ទាប់មកគេយល់ថា ត្រូវរួមបញ្ចូលការដាំបន្លែតាមផ្ទះ និងការធ្វើអោយប្រសើរឡើងនូវការអនុវត្តន៏ការងារកសិកម្ម ។

នៅក្នុងការវាយតំលៃ វាជាការល្អណាស់ បើគោលបំណងជាគោលបំណងជាក់លាក់ ច្បាស់លាស់ និងអាចវាស់វែងបាន។ មុននឹងការវាយតំលៃជាលក្ខណៈចូលរួមចាប់ផ្តើម វាជាការចាំបាច់ណាស់ដែលអ្នកចូលរួមធ្វើការវាយតំលៃត្រូវឯកភាពទៅលើគោលបំណង នៃកម្មវិធីជាមុនសិន ។

## ខ. ការបង្កើតក្រុមវាយតំលៃ

វាមានសារៈសំខាន់ណាស់ក្នុងការពិចារណា លើថាតើអ្នកណាគួរស្នើអោយចូលរួមអនុវត្តការវាយតំលៃ តើគេមានជំនាញក្នុងការប្រមូលពត៌មាន វិភាគ ដែលអាស្រ័យទៅនឹងគោលបំណងរបស់ការវាយតំលៃដែររឺទេ? បើក្រុមវាយតំលៃត្រូវប្រើប្រាស់នោះ តំរូវការដូចខាងក្រោមត្រូវបានពិចារណា :

- ក្រុមវាយតំលៃគួរត្រូវមានទាំងបុរស និងស្ត្រី
- ត្រូវមានអ្នកដែលមានបច្ចេកទេសដែលទាក់ទង ឧទាហរណ៍ សុខភាព កសិកម្ម.... ។

យើងដឹងហើយថា មានមនុស្សជាច្រើនដែលទទួលផលប្រយោជន៏ពីលទ្ធផល នៃការវាយតំលៃ ពេលនេះយើងនិយាយពីនរណាខ្លះ ដែលដើរតួនាទីក្នុងការអនុវត្តន៏ការវាយតំលៃ :

- សមាជិកសហគមន៏ដែលចូលរួមក្នុងកម្មវិធី : ជាទូទៅអ្នកទាំងនេះមិនមានការផ្តួចផ្តើមគំនិតក្នុងការវាយតំលៃឡើយ តែគេជាអ្នកដើរតួនាទីសំខាន់ក្នុងការអនុវត្តន៏ការវាយតំលៃ។ វាមានសារៈសំខាន់ណាស់ដែរគេបានចូលរួមយ៉ាងសកម្មក្នុងការកំណត់លើអ្វីមួយ, ពេលណា និងរបៀបណាដែលត្រូវធ្វើការវាយតំលៃ
- សមាជិកសហគមន៏ដែលមិនបានចូលរួមនៅក្នុងកម្មវិធី : ក្រុមផ្សេងៗនៅក្នុងសហគមន៏ គួរតែធ្វើការពិចារណា ដើម្បីអោយគេចូលរួមស្វែងយល់ និងផ្តល់ជាគំនិតផ្សេងៗដល់កម្មវិធី និងអាចធ្វើអោយគេមានការចាប់អារម្មណ៏ និងគេអាចចូលរួមជាងសមាជិករបស់យើងកាន់តែច្រើន ។
- បុគ្គលិកគំរោង
- អង្គការផ្សេងៗទៀតដែលធ្វើការនៅក្នុងតំបន់
- អ្នកសំរបសំរួលការវាយតំលៃ ។

អ្នកសំរបសំរួលពីខាងក្រៅ អាចជួយបង្កើតដំណើរការ បង្រៀនការអនុវត្តន៏ និងបង្កើនអោយមានភាពសត្យានុម័តកាន់តែខ្លាំង។ គេមានតួនាទីគ្រាន់តែជាអ្នកសំរបសំរួលប៉ុណ្ណោះ។ គេអាចផ្តល់នូវបទពិសោធន៏របស់គេ តែមិនអាចសន្និដ្ឋានលើអ្វីទាំងអស់ ។

## គ. ការជ្រើសរើសវិធីសាស្ត្រវាយតំលៃ

មានវិធីសាស្ត្រជាច្រើនដែលត្រូវបានគេប្រើប្រាស់នៅក្នុងការវាយតំលៃ ។ វិធីសាស្ត្រ ត្រូវបានប្រើប្រាស់សំរាប់វាយតំលៃពីឥទ្ធិពល នៃកម្មវិធីទៅលើប្រជាជន ខ្លះសំរាប់ជួយវាយតំលៃរចនាសម្ព័ន្ធអង្គការ និងកម្មវិធី, ខ្លះសំរាប់វាយតំលៃឥទ្ធិពល នៃសកម្មភាពកម្មវិធី ។

១. ប្រជាជន (វិធីសាស្ត្រដែលប្រើប្រាស់ជាទូទៅ)

- ឧបករណ៍វាស់វែង ដូចជា ជញ្ជីង ម៉ែត្រ....
- សំនួរផ្ទាល់មាត់ : សួរសំនួរក្នុងបញ្ជី, សំភាសន៍ធ្វើតេស្តជំនាញ និងចំណេះដឹង, ប្រជុំ, ការពិភាក្សា
- សំនួរសរសេរ : ជាបញ្ជីសំនួរ, ការធ្វើតេស្តជំនាញ, ចំណេះដឹង
- ការវិភាគពតិមានដែលមានស្រាប់ ដូចជារបាយការណ៍
- ការអង្កេត ថតរូប

២. រចនាសម្ព័ន្ធអង្គការ និងកម្មវិធី : ក៏ដូចជាវិធីដែលប្រើសំរាប់វាយតំលៃប្រជាជនដែរ ។

៣. សកម្មភាពកម្មវិធី : វិធីសាស្ត្រជាច្រើន ដែលអាចយកមកប្រើប្រាស់សំរាប់វាយតំលៃឥទ្ធិពល នៃសកម្មភាពកម្មវិធី រួមមាន :

- ការវាស់វែងផ្សេងៗ ដូចជាផ្ទៃដី ចំនួនមនុស្ស ផលិតផល
- ការធ្វើតេស្ត
- ការសួរសំនួរផ្ទាល់មាត់ រឺសរសេរ ។

## ឃ. ការបង្កើតផែនការវាយតំលៃ

ការធ្វើផែនការ គឺជាវិធីដែលរៀបចំដែលអ្នកអាចបង្ហាញថា តើអ្វីដែលអ្នកចង់សំរេច និងនៅពេលណា ។ ការធ្វើផែនការ អាចជួយអ្នកអោយ :

- ជ្រើសរើស និងផ្តល់អាទិភាពលើគោលបំណង នៃការវាយតំលៃ
- បង្ហាញពីប្រភេទ នៃវិធីសាស្ត្រផ្សេងៗដែលយើងត្រូវប្រើ
- សំរេចថា តើយើងត្រូវលំអិតទៅលើអ្វីខ្លះ?
- កំណត់ពីតួនាទីរបស់មនុស្សម្នាក់ៗក្នុងការវាយតំលៃ
- បង្ហាញពីរយៈពេល និងការចំណាយលើការវាយតំលៃ
- បង្ហាញពីទំនាក់ទំនង នៃផ្នែកផ្សេងៗក្នុងការវាយតំលៃ
- បង្កើនជំនាញក្នុងការធ្វើផែនការ និងការរៀបចំ

របៀបដែលល្អក្នុងការធ្វើផែនការវាយតំលៃ គឺត្រូវបញ្ជាក់ពីអ្វីដែលអ្នកត្រូវធ្វើលំដាប់របស់វា និងត្រូវការ

ពេល វេលាប៉ុន្មាន ។

ខាងក្រោមនេះ គឺជាគំរូតារាងផែនការវាយតំលៃ អាចមានលក្ខណៈខុសគ្នា ប៉ុន្តែមានចំនុចសំខាន់ៗ ប្រហាក់ប្រហែលគ្នា :

| ចំនុចចំបង | សន្ទស្សន៍/ពតិមាន ដែលត្រូវប្រមូល | វិធីសាស្ត្រប្រមូល | អ្នកណាចូលរួម | នៅពេលណា |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

## ខ. ការប្រមូលពត៌មាន

បន្ទាប់ពីការធ្វើផែនការរួច យើងចាប់ផ្តើមអនុវត្តនូវអ្វីដែលបានគ្រោងនៅក្នុងផែនការ ។ ខាងក្រោមនេះ គឺជាឯកសារផ្សេងៗ ដែលអាចទាក់ទងទៅនឹងការប្រមូលពតិមានរបស់អ្នក :

- សំណើរគំរោងកម្មវិធី
- ឯកសារផ្សេងៗដែលទាក់ទងទៅនឹងសំណើរ
- របាយការណ៍វាយតំលៃពីពេលមុន រឺរបាយការណ៍ស្ទាបស្ទង់ដែលធ្វើឡើងដោយអ្នកផ្សេងលើកម្មវិធីរបស់អ្នក ។
- ផែនទី នៃតំបន់គោលដៅ
- គោលបំណង នៃគំរោងកម្មវិធីដែលមានបច្ចុប្បន្ន
- អង្គការលេខរបស់អង្គការ
- របាយការណ៍ប្រជុំផ្សេងៗ
- របាយការណ៍ជំរឿន របាយការណ៍ប្រចាំឆ្នាំ
- ផែនការថវិកា និងរបាយការណ៍ថវិកា
- ថវិកាសំរាប់ការវាយតំលៃ
- ផ្សេងៗ ។

## ច. ការធ្វើរបាយការណ៍លទ្ធផលនៃការវាយតំលៃ

☛ **តើអ្វីខ្លះដែលត្រូវបង្ហាញក្នុងរបាយការណ៍ :**

- តើកម្មវិធីកំពុងប្រឹងប្រែងធ្វើអ្វី

- តើជាក់ស្តែងមានអ្វីកើតឡើង
- តើអ្វីដែលធ្វើបាន និងអ្វីដែលធ្វើមិនបាន តើមកពីមូលហេតុអ្វី ។

**☛ ចំនុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ក្នុងការសរសេររបាយការណ៍**

- ត្រូវសរសេរអោយបានខ្លី : របាយការណ៍ដែលវែង អាចមិនមានផលប្រយោជន៍ ដោយគេគ្មានពេលអាន
- ត្រូវសរសេរអោយបានច្បាស់ : ជៀសវាងប្រើពាក្យបច្ចេកទេសជ្រៅៗ ពិបាកយល់
- ប្រើឃ្លាខ្លីៗ : មិនត្រូវអោយលើសពី ២០ ពាក្យ (បើអាច គឺមិនលើសពី ១៦ពាក្យ) នៅក្នុងឃ្លានីមួយៗ, មិនត្រូវបញ្ចូលគំនិតច្រើននៅក្នុងឃ្លាតែមួយឡើយ ។
- រៀបចំឃ្លា និងប្រយោគអោយបានសមស្រប
- ត្រូវប្រើចំណងជើងធំ តូចទៅតាមលំដាប់លំដោយ
- សង្កត់ធ្ងន់ទៅលើពាក្យគន្លឹះៗ
- មានតំលៃទាប
- ធ្វើអោយទាន់ពេលវេលា

**☛ ទំរង់បែបបទ នៃរបាយការណ៍**

ទំរង់បែបបទ នៃរបាយការណ៍មានច្រើនប្រភេទ អាស្រ័យទៅនឹងការកំណត់របស់គេ ។ ខាងក្រោមនេះ គឺជាទំរង់បែបបទមួយ ដែលគេប្រើជាទូទៅ :

- គំរបក្រៅ
- សង្ខេប
- មាតិកា
- ពតិមានជាមូលដ្ឋាន
- គោលបំណង និងវិធីសាស្ត្រ នៃការវាយតំលៃ
- លទ្ធផល នៃការប្រមូល និងវិភាគទិន្នន័យ
- ការផ្តល់ទិន្នន័យ និងអនុសាសន៍ ។

# ការបញ្ចប់គំរោង
# Project Termination

## ១. សេចក្តីផ្តើម

គំរោងត្រូវបញ្ចប់ដោយផ្អែកលើហេតុផលជាមូលដ្ឋានសំខាន់ ២ គឺ : គំរោងជោគជ័យ ឬគំរោងបរាជ័យ ។ អ្នកគ្រប់គ្រងជាន់ខ្ពស់ជាម្ចាស់គំរោង និងជាអ្នកដែលចាត់ទុកគំរោង ជាការរៀបចំនូវរាល់កត្តារារាំង និងការប្រតិបត្តិនូវយុទ្ធសាស្ត្រគ្រប់គ្រង ដែលត្រូវតែបង្កើតនូវបរិយាកាសវប្បធម៌មួយ ដែលជំរុញលើកទឹកចិត្តគំរោងអោយទទួលបានជោគជ័យ ប៉ុន្តែអាចធ្វើអោយគំរោងបរាជ័យ ប្រសិនបើវាបាត់បង់នូវយុទ្ធសាស្ត្រដែលស័ក្តិសមសំរាប់គំរោងផែនការគ្រប់គ្រងទៅថ្ងៃអនាគត ។

## ២. គំរោងជោគជ័យ ឬបរាជ័យ

គំរោងជោគជ័យមានន័យថា គំរោងបានបំពេញទៅតាមខ្ទង់ចំណាយ ពេលវេលាកំនត់ និងគោលបំណងអនុវត្តបច្ចេកទេស និងបានធ្វើការរួមបញ្ចូលក្នុងការគ្រប់គ្រងក្រុមគោលដៅ ដើម្បីរួមចំណែកក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ពួកគាត់។ គំរោងជោគជ័យ មានន័យថា អង្គភាពទទួលបានជោគជ័យក្នុងការបំពេញតួនាទីរបស់ខ្លួនសំរាប់ថ្ងៃអនាគត ដោយមានយុទ្ធសាស្ត្រជាក់លាក់មួយ ដែលត្រូវបានរៀបចំ និងប្រតិបត្តិតាម ។

គំរោងដែលបរាជ័យមានន័យថា ជាគំរោងដែលខកខានមិនបានបំពេញទៅតាមខ្ទង់ចំណាយ ពេលវេលាកំណត់ និងគោលបំណងនៃការនុវត្តន៍បច្ចេកទេសរបស់ខ្លួន ឬវាមិនទទួលបាននូវអនាគតយូរអង្វែង ។

## ៣. មូលហេតុនៃការបញ្ចប់គំរោង

ក. លទ្ធផលគំរោង (ផលិតផល ឬសេវាកម្ម) ដែលបានផ្តល់ដល់ក្រុមគោលដៅ ។ បើសិនជាវាសមរម្យ នោះកិច្ចសន្យាផ្តល់សេវាកម្ម និងការរក្សាទុកអាចត្រូវបានគេចរចា និងបន្តទៅមុខទៀត ។

ខ. គំរោងមានការចំណាយលុយ និងពេលវេលាច្រើនលើសការកំណត់ ឬវាខកខានមិនបានធ្វើនូវដំណើរការណាមួយ ដែលគួរជាទីពេញចិត្តក្នុងការរក្សានូវគោលបំណងអនុវត្តន៍បច្ចេកទេសរបស់ខ្លួន ។

គ. យុទ្ធសាស្ត្ររបស់ម្ចាស់គំរោងត្រូវផ្លាស់ប្តូរ ដូចនេះហើយគំរោងនោះលែងមានយុទ្ធសាស្ត្រណាមួយ ដែលសក្តិសមនៅក្នុងអនាគតនៃម្ចាស់គ្រប់គ្រងគំរោងនោះទេ ។

ឃ. គោលដៅគំរោងត្រូវបានបាត់បង់ ជាហេតុនាំអោយស្នើនូវការបន្តផ្តល់ធនធាននោះស្ថិតនៅក្នុងភាពមន្ទិលសង្ស័យ ។

ង. បរិយាកាសមានការផ្លាស់ប្តូរ ត្រូវបានកើតឡើងដែលធ្វើអោយអនាគតនៃគំរោងនេះមានលក្ខណៈផ្ទុយគ្នា

ស្រលះពីការព្រាងទុក ។

ច. ការជឿនលឿននៃលក្ខណៈវិធីសាស្ត្រផ្សេងៗ ដែលត្រូវប្រើក្នុងគំរោង (ដូចជាការស្រាវជ្រាវ និងការអភិវឌ្ឍន៍) ត្រូវបានគេយល់ដឹងជាទូទៅ ហេតុដូចនេះហើយការផ្តល់មូលនិធិបន្ថែមនោះ គឺមិនអាចនឹងមានមកដល់នោះទេ។

ឆ. អាទិភាព នៃគំរោងវាមិនទាន់ខ្ពស់ បើប្រៀបធៀបនឹងអាទិភាពនៃគំរោងដទៃទៀត

ការកំនត់នូវព្រំដែនរវាងគំរោងនីមួយៗ បើផ្អែកលើស្ថានភាពទាំងនេះ គឺមិនទាន់ច្បាស់លាស់នោះទេ ។ ស្ថានភាពទាំងនេះកំរផ្តល់នូវក្របខ័ណ្ឌការងារសំរាប់ទៅរកការចោទសួរពីការបញ្ចប់នូវគំរោងដែលគេចមិនរួច ។

### ☞ ហេតុអ្វីត្រូវបញ្ចប់គំរោង ?

គំរោងភាគច្រើន មិនដែលសូវមានការចាប់ផ្តើមដែលមានលក្ខណៈស្រួចស្រាលនោះទេ ។ គំរោងឈានទៅជាវដ្តគំរោង ហើយជាការចំណាយលុយ ពេលវេលាពិត និងកំណត់នូវការអនុវត្តន៍គំរោង ដែលត្រូវបានដឹងកាន់តែច្រើនដោយអ្នកគ្រប់គ្រងជាន់ខ្ពស់ ពេលខ្លះត្រូវធ្វើការសំរេចចិត្តដោយចៀសមិនបាន ថាតើគួរតែបញ្ចប់គំរោងដែរឬទេ ។ ការបញ្ចប់គំរោងមិនគួរត្រូវបានគេចាត់ទុកថាជាការបរាជ័យ ប៉ុន្តែគួរតែជាការសំរេចយកយុទ្ធសាស្ត្រមួយ ដែលបានប្រតិបត្តិពេលដែលគំរោងមួយមិនបាន ឬមិនអាចទ្រទ្រង់នូវយុទ្ធសាស្ត្រគ្រប់គ្រងបាន ។

ការសំរេចចិត្តបញ្ចប់គំរោង មិនកើតឡើងដោយភាពប្រញាប់ប្រញាល់ពេកនោះទេ ប៉ុន្តែកើតឡើងដោយយឺតនៅក្នុងដំណើរនៃវដ្តគំរោង ដែលកើតចេញពីភាពឈ្លាសវៃ ដែលទទួលបានពីគំរោងក្នុងពេលត្រួតពិនិត្យគំរោង។ ជាអកុសលការបញ្ចប់គំរោង ជារឿយៗត្រូវបានអោយឃើញ ពីលទ្ធផលនៃការបរាជ័យរបស់នរណាម្នាក់ ។ មនុស្សមិនដែលចេះទទួលកំហុស ជារឿយៗមានតិចណាស់ ដែលទទួលយកមូលហេតុបរាជ័យ នៃគំរោងនោះជាមូលហេតុ នៃការបញ្ចប់គំរោង ។

ក្រៅពីនេះមានតំរូវការមួយទៀតក្នុងពេលដែលពិនិត្យលើគំរោង ដើម្បីវាយតំលៃ ថាតើយុទ្ធសាស្ត្រគំរោងត្រូវបន្ត ឬត្រូវតែបញ្ចប់ ។

## ៤. ប្រភេទនៃការបញ្ចប់គំរោង

ការបញ្ចប់គំរោង ដែលបញ្ជាក់ពីខាងដើមបំផុត គឺត្រូវមានរួមបញ្ចូលនូវពីររបៀបធំៗ គឺទីមួយ ការបញ្ចប់តាមលក្ខខណ្ឌនៃគំរោង គឺនៅពេលដែលគោលដៅនៃគំរោងទាំងនេះបានឆ្លើយតបតាមតំរូវការ និងទីពីរ គឺការបញ្ចប់ទៅដោយមិនសមស្របទៅតាមលក្ខខណ្ឌនៃគំរោង នៅពេលដែលការកំណត់បញ្ហានៃគំរោងមួយចំនួនត្រូវពន្លឿន ហើយការអនុវត្តន៍នេះ គឺធ្វើទៅមិនបានសមស្រប ឬក៏គោលដៅនៃគំរោងទាំងនេះមិនមានទំនាក់ទំនងយូរអង្វែងជាមួយនឹងតំរូវការទូទៅរបស់គំរោង ។

**ការស្តែងចេញដោយអារម្មណ៍ដែលពាក់ព័ន្ធទៅនឹងការបញ្ចប់នៃគំរោងរួមមាន :**

- ការភ័យខ្លាចចំពោះភាពគ្មានការងារធ្វើនាពេលអនាគត
- ការបាត់បង់នូវចំណាប់អារម្មណ៍ចំពោះការងារ ដែលបន្សល់ទុកនៅពេលក្រោយ
- ការបាត់បង់នូវសកម្មភាពក្រុម
- ការជ្រើសរើសនូវបុគ្គល ដែលត្រូវអោយលាឈប់
- ការចងក្រងនូវវិធីសាស្ត្រជាថ្មី
- មានការបែងចែកនូវចំណាប់អារម្មណ៍

## ៥. យុទ្ធសាស្ត្រនៃការបញ្ចប់

បើគំរោងត្រូវបញ្ចប់ អ្នកគ្រប់គ្រងជាន់ខ្ពស់មួយចំនួន នឹងជំនួសនូវអ្នកគ្រប់គ្រងគំរោងជាមនុស្សម្នាក់ ដែលមានជំនាញច្បាស់លើគំរោង។ ក្នុងនាមជាអ្នកគ្រប់គ្រង ការបញ្ចប់គរោងត្រូវតែឈ្លាស់វៃក្នុងការធ្វើការរំលឹកឡើងវិញនូវស្ថានភាពនៃកញ្ចប់ការងាររួមជាមួយមូលនិធិ កាលកំណត់ និងកំណត់នូវការអនុវត្តន៍បច្ចេកវិទ្យា ។ បញ្ហាមួយចំនួនដែលត្រូវតែសំរេចអោយបាន គឺ :

- ធានាថា ផលិតផលនៃគំរោងទាំងអស់ ត្រូវបានផ្តល់អោយដល់ម្ចាស់គំរោង និងរាល់ការងារនៃគំរោងទាំងអស់ត្រូវបានបញ្ចប់ដោយមានការកត់ត្រាច្បាស់លាស់ ។
- រំលឹកឡើងវិញនូវស្ថានភាពទាំងអស់នៃកិច្ចសន្យា ដើម្បីធានាថាតំរូវការត្រូវបានគេបំពេញ ឬការកំណត់ធ្វើ ប្រសិនបើការទាមទារនោះមិនត្រូវបានធ្វើការបំពេញបានសមគួរនៅឡើយ ។
- ការធ្វើការជាមួយក្រុមគំរោងក្នុងការអភិវឌ្ឍន៍ និងការបែងចែកនូវផែនការមួយ ដែលផ្តល់នូវគោលការណ៍សំរាប់ការបញ្ចប់នូវរាល់ធាតុផ្សំ នៃគំរោងតាមលំដាប់លំដោយ ។
- ការធានាអះអាងទៅលើការបន្តការឃ្លាំមើលទៅលើរាល់សកម្មភាព ដែលរួមទាំងការកត់ត្រា និងបទបញ្ញាតិនៃធនធាន ។
- សង្កេតពីអ្នកដែលចូលរួមពាក់ព័ន្ធនឹងការបញ្ចប់គំរោង ។
- ធានាថារាល់បញ្ហាហិរញ្ញវត្ថុ នៃគំរោងត្រូវបានបញ្ចប់ប្រកបដោយភាពដែលអាចយកជាការបាន ។
- ជួយដល់សមាជិកក្រុមគំរោង ដើម្បីស្វែងរកការងារថ្មីសំរាប់ធ្វើនៅក្នុងការគ្រប់គ្រង ។
- រៀបចំនូវប្រវត្តិនៃគំរោង ជាពិសេសរបាយការណ៍នៃមេរៀនដែលបានរៀន ដែលក្រុមអនាគតនៅក្នុងការគ្រប់គ្រង អាចទទួលផលនូវបទពិសោធន៍ផ្សេងៗពីគំរោង ។
- ធ្វើសវនកម្មលើគំរោងអោយមុនពេលបញ្ចប់ដើម្បីកំណត់ពីភាពខ្លាំង និងភាពខ្សោយនៃការគ្រប់គ្រងគំ-រោង ដើម្បីដឹងពីកំហុសដែលជាផលប៉ះពាល់អ្វីខ្លះដែលមាន ហើយថាកំហុសនេះអាចធ្វើប៉ះពាល់ដល់

អនាគតនៃគំរោង និងការគ្រប់គ្រងនោះអាចទទួលផលប៉ះពាល់ដែរឬទេ? តើវាមានលក្ខណៈវិជ្ជមានចំពោះគំរោង ។

# ការណែនាំដំបូងអំពីការបង្កើតសំណើរគំរោង
# Guideline for Proposal Preparation

សំណើរគំរោង (Proposal) គឺជាផែនការដែលត្រូវបានស្នើឡើង និងបញ្ជូនទៅប្រភពផ្តល់មូលនិធិនានា ដើម្បីធ្វើការពិនិត្យពិចារណា ក្នុងការគាំទ្រ។ គោលបំណង នៃគំរោងសំណើរ គឺ :

- ដើម្បីទទួលបានថវិកាសំរាប់អង្គការ និងការងាររបស់អ្នក
- ដើម្បីធានាបាននូវការបង្កើនទុនថែមទៀតពីសំណាក់ម្ចាស់ជំនួយ
- ដើម្បីផ្សព្វផ្សាយឈ្មោះក្នុងវិស័យដែលជាជំនាញរបស់អង្គការអ្នក
- ដើម្បីបង្ហាញពីលទ្ធផលជាក់ស្តែង
- ដើម្បីតំរង់ទិសសកម្មភាពទាំងឡាយរបស់អ្នកឆ្ពោះទៅរកផលសំរេច នៃគោលដៅ
- ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានអោយកាន់តែប្រសើរឡើង ។
-

## ☞ ទំរង់/បែបបទ នៃគំរោងសំណើរ

មានទំរង់/បែបបទច្រើន មិនមែនមានគំរូតែមួយទេក្នុងការសរសេរសំណើរគំរោង ។ ប៉ុន្តែយ៉ាងណាក៏ដោយក៏មានសមាសភាគមួយចំនួនជាសកល ដែលយើងអាចថ្លឹងថ្លែងទៅនឹងស្ថានភាពបច្ចុប្បន្ន និងការទាក់ទងរបស់អ្នកជាមួយភ្នាក់ងារជំនួយ។ សំណើរគំរោងណាក៏ដោយ ទោះមាន រឺមិនមាន Logframe ក៏សុទ្ធតែបានប្រាប់ទៅម្ចាស់ជំនួយអំពី :

- អ្នកជាអ្នកណា (Introduction)
- អ្វីដែលអ្នកចង់ធ្វើ (Objective)
- អ្នកនឹងធ្វើអ្វីនៅឯណា ដោយរបៀបណា (Activities)
- មូលហេតុដែលអ្នកចង់ធ្វើ (Problem Statement) និងធនធានដែលត្រូវការសំរាប់អនុវត្ត (Budget) ចំនុចសំខាន់ៗត្រូវបកស្រាយអោយបានច្បាស់ត្រឹមត្រូវ បញ្ជាក់ដោយពាក្យច្បាស់ៗ ។ ឯកសារត្រឹមត្រូវពិតមានហេតុផលដើម្បីឈានទៅរកតុល្យភាព និងភាពសមស្របសំរាប់សំណើរគំរោងរបស់អ្នក ។

## តំរូវការពីភ្នាក់ងារជំនួយ :

ម្ចាស់ជំនួយជាច្រើន មានគោលការណ៍ណែនាំ និងតំរូវការ ។ ជាការប្រសើរណាស់ ដែលត្រូវបំពេញទំរង់ និងខ្លឹមសារ នៃតំរូវការចាំបាច់នោះ ព្រោះថានឹងបង្ហាញម្ចាស់ជំនួយថាអ្នកកំពុងស្តាប់ និងទទួលយកដំបូន្មានរបស់គេយ៉ាង

ម៉ត់ចត់ ។

### ☞ ការដាក់ពាក្យសុំលើកទីមួយ

ប្រសិនបើម្ចាស់ជំនួយមិនទាន់ស្គាល់អ្នកច្បាស់ទេនោះ អ្នកគួរផ្តល់ពត៌មានពីអ្នកអោយបានច្រើនបន្ថែមទៀត។ ម្យ៉ាងទៀត បើតំបន់នៃគំរោងអ្នកជាកន្លែងថ្មី រឺមានការផ្លាស់ប្តូរខុសប្លែកពីឆ្នាំមុនៗ អ្នកក៏គួរផ្តល់បន្ថែមពត៌មានអំពីព្រឹត្តិការណ៍នោះដែរ ។

### ☞ ការដែលបានស្គាល់ម្ចាស់ជំនួយរួចហើយ

ពេលដែលអ្នកបង្កើតទំនាក់ទំនង ជាមួយម្ចាស់ជំនួយបានហើយ រឺម្ចាស់ជំនួយនៅធ្វើការរួមគ្នាជាមួយអ្នក ក្នុងតំបន់ រឺមកប្រទេសយើងញឹកញាប់ នោះការរៀបរាប់ពត៌មានអំពីប្រវត្តិ មិនចាំបាច់នឹងត្រូវរៀបរាប់ថែមទៀតទេ ។

### ☞ ការពង្រីកសេវា/ក្រុមគោលដៅ រឺតំបន់សេវា

ត្រង់នេះ តំរូវការអោយបន្ថែមពត៌មានទៀត លើសពីសំណើរមុន ដែលបញ្ជាក់ពីពត៌មានសំខាន់ៗ ដែលបណ្តាលអោយមានភាពផ្លាស់ប្តូរ ហើយក៏ត្រូវរៀបរាប់ពីសកម្មភាពវិធីសាស្រ្ត រឺរបៀបថ្មីៗថែមទៀតផងដែរ ។

## គំរូទំរង់បែបបទសំរាប់ការសរសេរសំណើរគំរោង

មានសំណើរគំរោងជាច្រើនត្រូវបានសរសេរនៅក្នុងទំរង់បែបបទផ្សេងៗគ្នា ប៉ុន្តែទោះបីជាយ៉ាងណា ទំរង់បែបបទទាំងនោះមានចំនុចរួមសំខាន់ៗដូចគ្នា ហើយដែលយើងអាចយកទំរង់មួយធ្វើជាគំរូ ដែលមានលំដាប់លំដោយដូចតទៅ :

- ទំព័រចំណងជើង
- ខ្លឹមសារសង្ខេប
- បញ្ជីមាតិកា
- សន្ទានុក្រម
- សេចក្តីផ្តើម
- បំណកស្រាយបញ្ហា
- គោលបំនង
- វិធីសាស្រ្ត (សកម្មភាព)
- គំរោងថវិកាសង្ខេប
- ផែនការ ត្រួតពិនិត្យ វាយតំលៃ និងរបាយការណ៍

- ឯកសារភ្ជាប់ផ្សេងៗ ។

## ក. ទំព័រចំណងជើង :

- ចំណងជើងគំរោង
- ឈ្មោះម្ចាស់ជំនួយ អស័យដ្ឋាន លេខទូរស័ព្ទ និងលេខទូរសារ សារអេឡិចត្រូនិច
- ឈ្មោះអង្គការ អស័យដ្ឋាន លេខទូរស័ព្ទ និងលេខទូរសារ សារអេឡិចត្រូនិច
- បុគ្គលសំរាប់ទំនាក់ទំនង
- កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់កម្មវិធី ។

☞ **កំហុស :**

- អក្សរទំហំធំពេក
- ប្រើប្រាស់ពណ៌ច្រើនពេក
- ប្រើប្រាស់ប្រភេទអក្សរច្រើនបែបពេក ។

## ខ. ខ្លឹមសារសង្ខេប :

គឺជាទំព័រសំខាន់មួយ ដែលម្ចាស់ជំនួយចាប់អារម្មណ៍អានមុនគេ ។ នៅក្នុងទំព័រនេះ ត្រូវសរសេរបញ្ចូលនូវ :

- ការពិពណ៌នាសង្ខេបពីកម្មវិធី និងអត្តសញ្ញាណរបស់អង្គការ
- បង្ហាញដោយសង្ខេបអំពីបញ្ហាដែលត្រូវដោះស្រាយ
- សរសេរគោលបំណង និងសកម្មភាពសំខាន់ៗ
- បង្ហាញពីវិធីសាស្ត្រដើម្បីអភិវឌ្ឍន៍កម្មវិធី
- ពិពណ៌នានូវចំនួនប្រជាជនដែលនឹងទទួលឥទ្ធិពល
- បង្ហាញពីតំរូវការថវិកាសរុប នៃកម្មវិធី
- បង្ហាញពីធនធានដែលមានស្រាប់ និងធនធានដែលត្រូវស្នើរសុំ

ខ្លឹមសារសង្ខេបនេះ គេត្រូវសរសេរវានៅពេលដែលបានបញ្ចប់ការសរសេរអត្ថបទសំណើរគំរោង

☞ **ចំនុចល្អ :** ខ្លឹមសារសង្ខេប នៃសំណើរគំរោងដែលល្អ គួរសរសេរត្រឹមមួយទំព័រតែប៉ុណ្ណោះ

☞ **កំហុស :**

- មានគោលបំណងច្រើនពេក

- គ្មានការទាក់ទងគ្នារវាងសកម្មភាព និងគោលបំណង
- គ្មានការនិយាយបកស្រាយដែលបង្ហាញពីភាពជឿជាក់ទៅលើអង្គការអ្នក ។

## គ. បញ្ជីមាតិកា

គឺជាទំព័រមួយដែលបង្ហាញនូវចំណងជើងសំខាន់ៗក្នុងសំណើរគំរោង។ បញ្ជីនេះ នឹងធ្វើអោយអ្នកផ្តល់ជំនួយងាយស្រួលក្នុងការរកផ្នែកណាមួយដែលចង់ដឹង មុននឹងធ្វើការពិភាក្សាជាមួយអ្នកស្នើសុំ ។

## ឃ. សន្ទានុក្រម

បញ្ជីនេះ ត្រូវបានបន្ថែមទៅក្នុងសំណើរគំរោង ដើម្បីពន្យល់ទៅម្ចាស់ជំនួយ នូវពាក្យកាត់ រឺពាក្យដែលបញ្ជាក់ពីន័យបច្ចេកទេស រឺពាក្យតាមតំបន់។ល។ ដែលបានប្រើប្រាស់ក្នុងសំណើរគំរោង។ ពេលខ្លះ បញ្ជីនេះស្ថិតនៅខាងក្រោយដូចឯកសារភ្ជាប់ដែរ ។

## ង. សេចក្តីផ្តើម

គឺជាការរៀបរាប់ពីតំបន់របស់គំរោង រួមមានភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម នយោបាយ បរិស្ថាន ត្រូវផ្តល់ពតិមានស្ថិតិ ដែលមានប្រភព និងកាលបរិច្ឆេទច្បាស់លាស់។ ចំនុចសំខាន់មួយទៀត ត្រូវសរសេរអំពីបទពិសោធន៍អង្គការរបស់អ្នក ដោយបញ្ជាក់អំពីការចាប់ផ្តើរបស់អង្គការ គោលដៅ និងគោលបំណងរបស់អង្គការ ប្រភពថវិកា លទ្ធផលវាយតំលៃ ផលសំរេច និងអំណះអំណាងដទៃទៀត ដែលបង្ហាញអំពីសមត្ថភាពរបស់យើង។ ប្រសិនបើសំណើរនេះ សរសេរសំរាប់អ្នកដែលធ្លាប់បានផ្តល់ជំនួយដល់យើង ការរៀបរាប់អំពីប្រវត្តិរបស់អង្គការមិនសូវជាសំខាន់ប៉ុន្មានទេ ប៉ុន្តែត្រូវប្រាប់អំពីទិន្នន័យ នៃការវាយតំលៃពីកម្មវិធីលើកមុនប្រសើរជាង។ ត្រូវចងចាំថា មិនត្រូវសរសេរអ្វីដែលគ្មានប្រភពច្បាស់លាស់ទេ ។

## ច. សេចក្តីថ្លែងពីបញ្ហា

កំណត់បញ្ហាអោយបានគ្រប់គ្រាន់ ដោយផ្អែកទៅលើការវិភាគស្ថានភាព រឺការប៉ាន់ស្មានពីតំរូវការ ។

☞ **ប្រវត្តិ នៃបញ្ហា :**

- ប្រភេទ និងទំហំនៃបញ្ហា
- រៀបរាប់ពីអ្នកទទួលរងឥទ្ធិពលពីបញ្ហានេះ
- បង្ហាញអោយបានច្បាស់ពីឯកសារដែលពាក់ព័ន្ធនឹងបញ្ហា

- បង្ហាញពីគោលនយោបាយថ្នាក់ជាតិ រឺថ្នាក់តំបន់ និងកម្មវិធីផ្សេងៗ ដែលមានទំនាក់ទំនងទៅនឹងបញ្ហា និងរបៀបដោះស្រាយ
- បង្ហាញទំនាក់ទំនងពិសេសជាមួយការងារដទៃ រឺអង្គការនានា និងការរៀបចំផ្សេងៗអោយមានដំណើរការល្អ
- ថ្លែងទាំងបញ្ហា ទាំងតំរូវការអោយបានជាក់លាក់ ។

### ☞ រៀបរាប់អំពីបញ្ហាដែលគំរោងលើកយកមកដោះស្រាយ

- អ្វីទៅជាបញ្ហា រឺតំរូវការដែលត្រូវយកមកអនុវត្ត ( មានទាំងពីរ គឺរយៈពេលខ្លី រឺវែង)
- តើកំណត់អត្តសញ្ញាណ នៃបញ្ហាពីមុនមកយ៉ាងដូចម្តេច? និងមានវិធីសាស្ត្រដោះស្រាយយ៉ាងដូចម្តេច?
- តើយើងទទួលបានបទពិសោធន៍អ្វីខ្លះពីជោគជ័យ រឺបរាជ័យ និងការវាយតំលៃ ។

យើងត្រូវសន្មត់ថា អ្នកអានមិនដឹងច្បាស់ពីស្ថានភាពផ្សេងៗក្រៅពីអ្វីដែលយើងបានរៀបរាប់មកនោះទេ ។ អ្នកអានចង់ដឹងច្បាស់អំពីបញ្ហាទាំងអស់ តែគេមិនចង់អានការរៀបរាប់ទូលំទូលាយ នៃបញ្ហារបស់សហគមន៍ទេ ត្រូវសរសេរខ្លីៗ តែមានន័យច្បាស់លាស់ ត្រូវតែពិត ហើយឯកសារមានន័យគ្រប់គ្រាន់។ បង្ហាញពីទិន្នន័យ ដែលមានប្រភពពីអង្គការសហប្រជាជាតិ របាយការណ៍រាជរដ្ឋាភិបាល អង្គការនានា អ្នកដឹកនាំសហគមន៍ អ្នកសង្កេតការណ៍ដែលមានចំណេះដឹងជាដើម រាប់បញ្ចូលទាំងទិន្នន័យដែលមានប្រភពសិក្សាជាផ្លូវការ និងសហគមន៍។ ប្រើប្រាស់អំណះអំណាងពិត និងតាមបច្ចេកទេស ដែលផ្អែកទៅលើការស្រង់ចេញពីស្ថិតិនានា ។

## ឆ. វិធីសាស្ត្រ (សកម្មភាព)

- មាននៅក្នុងLogframe
- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គការ ដើម្បីអោយសំរេចគោលបំណងដែលបានលើកឡើង
- របៀបដែលគេនឹងធ្វើការសំរបសំរួល រឺសហការការងារគ្នា
- ការចូលរួមរបស់សហគមន៍
- វិធីសាស្ត្រ និងបច្ចេកទេសជាក់លាក់ដែលត្រូវប្រើ
- កាលបរិច្ឆេទអនុវត្តការងារ និងផែនការការងារ ។

## ជ. គំរោងថវិកាសង្ខេប

- ពិពណ៌នាពីអ្នកផ្តល់ថវិកា ( អជ្ញាធរក្នុងតំបន់ អង្គការផ្សេងៗទៀត...)

- ពិពណ៌នាការចំណាយថវិកាសរុប នៃសកម្មភាពចំបងដែលទាក់ទងទៅនឹងគោលបំណង
- គ្រប់ខ្ទង់ចំណាយសំខាន់ៗ គួរពន្យល់ជាសាច់ប្រាក់សុទ្ធ

☞ **ចំនុចល្អ :** គំរោងថវិកាដែលច្បាស់លាស់ ជួយកសាងភាពជឿជាក់ពីម្ចាស់ជំនួយ

☞ **កំហុស :**

- កំណត់តំលៃលើសពីការពិតខ្លាំងពេក
- មានភាពទូលំទូលាយពេក គ្មានការទាក់ទងជាមួយសកម្មភាព
- មិនបានបង្កអោយមានភាពងាយស្រួលសំរាប់ការត្រួតពិនិត្យ ។

## ឈ. ផែនការត្រួតពិនិត្យ វាយតំលៃ របាយការណ៍

**ផែនការវាយតំលៃ ត្រូវ :**

- ពិពណ៌នានូវប្រភេទ នៃការវាយតំលៃដែលនឹងអនុវត្ត
- វិធីសាស្រ្តដែលនឹងប្រើ
- នរណាខ្លះចូលរួម
- កំរិត និងប្រភេទនៃការចូលរួម
- កាលបរិច្ឆេទវាយតំលៃ
- ការចាយវាយសំរាប់ការវាយតំលៃ ។

**ផែនការត្រួតពិនិត្យ ត្រូវ :**

- ពិពណ៌នាអំពីពត៌មានដែលត្រូវប្រមូល
- នីតិវិធីសំរាប់ការប្រមូលពត៌មាន
- ពិពណ៌នាអំពីនីតិវិធី នៃការកែសំរួលការអនុវត្តន៏កម្មវិធី ។

**ផែនការធ្វើរបាយការណ៏ :** ត្រូវប្រាប់នូវខ្លឹមសារសំរាប់ធ្វើរបាយការណ៏ និងពេលវេលា នៃការធ្វើរបាយការណ៏ និងការចែកចាយ ។

## ៣. ឯកសារភ្ជាប់ (ឧបសម្ព័ន្ធ)

ឯកសារដែលត្រូវភ្ជាប់បន្ថែម អាចជាផែនទីគំរោង រូបថត រឺគំនូរបច្ចេកទេសផ្សេងៗ, តារាង Logframe, តារាងផែនការសកម្មភាព, ប្រវត្តិរូប និងប្រវត្តិការងាររបស់មនុស្សសំខាន់ៗនៃកម្មវិធី, ឯកសារវាយតំលៃដោយអ្នកខាងក្រៅថ្មីៗ, លិខិតគាំទ្រពីរដ្ឋាភិបាល រឺសហគមន៍, កិច្ចសន្យាដោយអង្វាធរ, លក្ខ័ណ្ឌ និងកិច្ចព្រមព្រៀងផ្សេងៗ ។

# ឯកសារយោង

# REFERENCES

**Jan-Willem Rosenboon, 1998.** Project Planning, Monitoring and Evaluation. Training Manual, Phnom Penh Cambodia

**Reidar Dale.** Evaluation Frameworks for Development Programs and Projects, Sage Publications. New Delhi/Thousand Oaks/London, 1998

**Wickramanayake, Ebel,** Identify Projects, Asian Institute of Technology, Bangkok, 1998

**Wickramanayak, Ebel,** Project Planning with People's Participation, Development in Practice, 1994

**Dusseldorp, van D. and K.Zijiderveld,** The Preparation and Implementation of Porjects in Developing Country, University of Wageningen, 1984